

# ការផ្សព្វផ្សាយកែលម្អ ការចិញ្ចឹមទារក និង កុមារតូច នៅក្នុងសហគមន៍ ប្រទេសកម្ពុជា

កូនខ្ញុំសុខភាពល្អ ដោយសារបបរខាប់គ្រប់គ្រឿង

## មគ្គុទ្ទេសក៍សម្រាប់អ្នកសម្របសម្រួល

Malteser International
Order of Malta Worldwide Relief

សហភាពអឺរ៉ុប

FIAT PANIS

# ការផ្សព្វផ្សាយកែលម្អការចិញ្ចឹមទារកនិងកុមារតូច នៅក្នុងសហគមន៍ប្រទេសកម្ពុជា

## មគ្គុទ្ទេសក៍សម្រាប់អ្នកសម្របសម្រួល

### អំពីមគ្គុទ្ទេសក៍នេះ

មគ្គុទេសក៍សម្រាប់អ្នកសម្របសម្រួលបានចងក្រងឡើងសម្រាប់អ្នកផ្សព្វផ្សាយអាហារូបត្ថម្ភនៅសហគមន៍(CNP)ដើម្បីសម្របសម្រួលក្នុងការអប់រំជាក្រុមស្តីពីការលើកកម្ពស់ ការចិញ្ចឹម និងគាំពារទារក និងកុមារ ជាមួយនឹងអ្នកថែទាំកុមារនៅតាមសហគមន៍ក្នុងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារនៅភាគឦសាននៃប្រទេសកម្ពុជា។ អត្ថន័យមេរៀនដែលបានបង្ហាញនៅក្នុងមគ្គុទ្ទេសក៍នេះ បានចងក្រងឡើងដោយយោងទៅតាមឯកសារបណ្តុះបណ្តាលពីការលើកកម្ពស់ និងគាំទ្រការចិញ្ចឹមនិងថែទាំទារក និងកុមារតូចៗនៅក្នុងសហគមន៍ស្រលាញ់ទារករបស់កម្មវិធីជាតិអាហារូបត្ថម្ភនៃក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

បញ្ចីមុខអាហារត្រូវបានរៀបចំ សាកល្បង និងកែលម្អដោយក្រុមការងារមន្ត្រីក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិនៅក្នុងខេត្តទាំង ៩ រួមមានខេត្តកំពង់ស្ពឺ តាកែវ ព្រៃវែង ស្វាយរៀង កំពង់ធំ ព្រះវិហារ បន្ទាយមានជ័យ សៀមរាប និងឧត្តរមានជ័យ ក្រោមគម្រោង "កែលម្អសន្តិសុខស្បៀងគ្រួសារក្រីក្រដែលងាយរងគ្រោះដោយសារការឡើងថ្លៃស្បៀងអាហារ" ដែលទទួលថវិការគាំទ្រដោយសហភាពអឺរ៉ុប។

# តារាងមាតិកា


**វគ្គបណ្តុះបណ្តាល លើកទី ១ ៖ ..........................................................៤**

**មេរៀនទី ១៖** ការណែនាំ និងការបញ្ចាំងវីដេអូបង្រៀនពីការរៀបចំ បបរខាប់ គ្រប់គ្រឿង និងសារៈសំខាន់នៃការផ្តល់អាហារបន្ថែម..........៥

**មេរៀនទី ២៖** ការបន្តបំបៅកូនដោយទឹកដោះម្តាយ................................៦

**មេរៀនទី ៣៖** អាហារូបត្ថម្ភសម្រាប់ម្តាយដែលបំបៅកូនដោយទឹកដោះ.......៨

**មេរៀនទី ៤៖** ភាពចម្រុះមុខអាហារ ៖ អាហារបីក្រុម.......................... ១០

**វគ្គបណ្តុះបណ្តាល លើកទី ២ ៖........................................................១៣**

**មេរៀនទី ៥៖** ការរៀបចំអាហារប្រកបដោយអនាម័យ.......................... ១៤

**មេរៀនទី ៦៖** ការលាងដៃជាមួយទឹកស្អាត និងសាប៊ូ.......................... ១៦

**មេរៀនទី ៧៖** របៀបរៀបចំអាហារបន្ថែម៖ វគ្គ ១................................ ១៨

**មេរៀនទី ៨៖** របៀបរៀបចំអាហារបន្ថែម៖ វគ្គ ២ ................................២០

**វគ្គបណ្តុះបណ្តាល លើកទី ៣ ៖ .......................................................២៣**

**មេរៀនទី ៩៖** អាហារក្រៅពេល (ផ្លែឈើ) .........................................២៤

**មេរៀនទី ១០៖** អាហារបន្ថែមសមស្របតាមក្រុមអាយុកុមារ....................២៦

**មេរៀនទី ១១៖** ការបញ្ចុកអាហារបន្ថែមដោយសកម្ម ............................២៨

*ចម្អិនអាហារបង្ហាញ ទី១៖ ការចម្អិនអាហារបង្ហាញជាមួយ*

អង្ករ សាច់ត្រី និងស្លឹកម្រុំ .......................................................៣០

**វគ្គបណ្តុះបណ្តាល លើកទី ៤៖ .......................................................៣១**

*ចម្អិនអាហារបង្ហាញ ទី២៖ ការចម្អិនអាហារបង្ហាញជាមួយ*

១. ដំឡូងជ្វា សណ្តែកដី និងផ្ទី .................................................៣២

២. ត្រាវ ស៊ុត និងស្ពៃចង្កឹះ....................................................៣២

**វគ្គបណ្តុះបណ្តាល លើកទី ៥៖ ....................................................... ៣៣**

*ចម្អិនអាហារបង្ហាញ ទី៣៖ ការចម្អិនអាហារបង្ហាញជាមួយ*

១. អង្ករ ថ្លើមជ្រូក និងស្លឹកបាស..............................................៣៤

២. អង្ករ សាច់មាន់ និងត្រកួន .................................................៣៤

**វគ្គបណ្តុះបណ្តាល លើកទី ៦៖ .......................................................៣៥**

**មេរៀនទី ១២៖** ការចិញ្ចឹមកុមារក្នុងពេលឈឺអាយុចាប់ពី៦ខែ .................៣៦

**មេរៀនទី ១៣៖** របៀបរៀបចំអាហារបន្ថែម ដោយយកចេញពី អាហារប្រចាំថ្ងៃរបស់គ្រួសារ ......................................៣៨

*ចម្អិនអាហារបង្ហាញ ទី៤៖ ការចម្អិនអាហារបង្ហាញ ដោយយកចេញពីអាហារគ្រួសារ*

បាយជាមួយសម្លប្រហើរសាច់ត្រី............................................. ៤០

**វគ្គបណ្តុះបណ្តាល លើកទី ៧៖ ....................................................... ៤១**

**មេរៀនទី ១៤៖** ការរំលឹកសារគន្លឹះ................................................៤២

**មេរៀនទី ១៥៖** ពិធីចែកប័ណ្ណសរសើរ ............................................ ៤៤

**ឧបសម្ព័ន្ធ ១ ...................................................................... ៤៥**

បញ្ជីមុខអាហារសម្រាប់ការចម្អិនអាហារបង្ហាញ និងតារាងអនុសាសន៍ការរៀបចំអាហារ និងបញ្ចុក ............................... ៤៥

**ឧបសម្ព័ន្ធ ២ ...................................................................... ៥០**

តារាងតាមដានសម្រាប់លើកកម្ពស់ការផ្សព្វផ្សាយកែលម្អការចិញ្ចឹមទារក និងកុមារតូចនៅសហគមន៍................................................ ៥០

# វគ្គបណ្ដុះបណ្ដាល លើកទី ១

## សម្ភារៈត្រូវការ

### មុនចាប់ផ្ដើមមេរៀនអ្នកត្រូវ៖

- រៀបចំមេរៀនដោយការអានសន្លឹកផ្ទាត់ដែលត្រូវបង្រៀន
- ទូរទស្សន៍ និងវីដេអូបបរខាប់គ្រប់គ្រឿង
- សន្លឹកផ្ទាត់
- ក្រដាសផ្ទាំងធំ
- ហ្វឺតសរសេរ លើក្ដារខៀន/លើក្រដាស់ផ្ទាំងធំ
- ស្កុត




ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# មេរៀនទី១. ការណែនាំ និងការបញ្ចាំងវីដេអូបង្រៀនពីការរៀបចំបបរខាប់គ្រប់គ្រឿង និងសារៈសំខាន់នៃការផ្តល់អាហារបន្ថែម

**វត្ថុបំណង៖** រៀបរាប់ពីជាតុផ្សំសំខាន់ៗ នៃអាហារបន្ថែម និងហេតុអ្វីបានជាត្រូវការអាហារបន្ថែម និងការបន្តបំបៅកូនដោយទឹកដោះម្តាយវាសំខាន់ សម្រាប់ការលូតលាស់ សុខភាព និងការអភិវឌ្ឍន៍របស់កុមារ។

## ១ ណែនាំខ្លួនរបស់អ្នក និងប្រធានបទមេរៀន (៥នាទី)

អរុណសួស្តី ខ្ញុំឈ្មោះ.......................................។ ខ្ញុំគឺជាក្រុមទ្រទ្រង់សុខភាពភូមិ................................ ហើយខ្ញុំនឹងពិភាក្សាជាមួយអ្នកពីរបៀបចិញ្ចឹមនិងថែទាំទារកនិងកុមារតូចអាយុចាប់ពី ៥ ទៅ ១៨ ខែ។ ខ្ញុំនឹងជួបអ្នកទាំងអស់គ្នារៀងរាល់ ១ ឬ ២សប្តាហ៍ម្តងក្នុងអំឡុងពេល ៧ ទៅ ១៤ សប្តាហ៍។ យើងនឹងពិភាក្សាលើប្រធានបទផ្សេងៗទាក់ទងការចិញ្ចឹមកុមារ។ ហើយខ្ញុំមកទីនេះដើម្បីជួយអ្នកទាំងអស់គ្នារៀន និងឆ្លើយសំនួរទាំងឡាយដែលអ្នកមាន ដូច្នេះហើយសូមកុំមានការខ្លាចរអាក្នុងការសួរ សំនួរដែលអ្នកមិនច្បាស់។

**តើអ្នកមានសំនួរអ្វីទេ មុនពេលយើងចាប់ផ្តើមមេរៀន?**

## ២ ចាក់វីដេអូបង្ហាញ (២០នាទី)

**ពន្យល់ពីវីដេអូដែលនឹងចាក់បញ្ចាំងជូនអ្នកថែទាំកុមារ៖**

ជាការចាប់ផ្តើម យើងនឹងទស្សនាវីដេអូទាំងអស់គ្នាស្តីពីការចិញ្ចឹម និងថែទាំទារក និងកុមារតូច។ សូមទស្សនា និងស្តាប់ដោយយកចិត្តទុកដាក់។ សូមសួរសំនួរនៅពេលវីដេអូបញ្ចប់។

## ៣ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (១៥នាទី)

**សួរអ្នកថែទាំកុមារអំពីវីដេអូ និងពិភាក្សាអោយបានផុសផុលជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖**

1) តើវីដេអូនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) តើមានគ្រឿងផ្សំណាខ្លះដែលអ្នកអាចយកមកធ្វើបបរខាប់គ្រប់គ្រឿងបាន?
3) តើភាពខាប់របស់បបរដែលអ្នកបញ្ចុកកុមារ ខុសគ្នារបៀបណាពីបបរដែលអ្នកបានឃើញក្នុងវីដេអូ?
4) តើអ្នកបញ្ចុកកូនរបស់អ្នករបៀបណាពេលនៅផ្ទះ?

## ៤ ពន្យល់ទៅអ្នកថែទាំកុមារ (៥នាទី)

**ពន្យល់ពីវីដេអូ៖**

- យើងទើបតែបានទស្សនាវីដេអូស្តីពីការចិញ្ចឹម និងថែទាំទារក និងកុមារតូចដែលនិយាយពីការចិញ្ចឹមទារកចាប់ពីអាយុ ៥ខែ ទៅ។

**ពន្យល់ពីផែនការមេរៀនបន្ទាប់៖**

យើងនឹងពិនិត្យឡើងវិញពីអ្វីដែលអ្នកបានឃើញ នៅក្នុងវីដេអូនៅមេរៀនលើកក្រោយជាបន្តបន្ទាប់។ យើងក៏អាចពិភាក្សា និងអនុវត្តពីរបៀបធ្វើអាហារល្អៗសម្រាប់កូនរបស់អ្នក។

**(ពេលវេលាសរុប ៤៥នាទី)**

# មេរៀនទី២. ការបន្តបំបៅកូនដោយទឹកដោះម្តាយ

**ទិវត្ថុបំណង៖** សិក្ខាកាមអាចរៀបរាប់បានពី៖ ការបន្តបំបៅកូនដោយទឹកដោះម្តាយរហូតដល់កុមារអាយុ ២ឆ្នាំ ឬ លើស គឺសំខាន់សម្រាប់ការលូតលាស់សុខភាព និងការអភិវឌ្ឍន៍របស់កុមារ។

## ១ បង្ហាញសន្លឹកផ្ទាត់ (៥នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**ផ្ទាំងរូបភាពទី១**



បន្តបំបៅដោះកូនរហូតដល់ កូនរបស់អ្នកអាយុ២ឆ្នាំ ឬលើស

## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (១៥នាទី)

សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុលជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) តើម្តាយគួរបន្តបំបៅកូនដោយទឹកដោះម្តាយរហូតដល់អាយុប៉ុន្មាន?
3) តើនៅអាយុប៉ុន្មានទើបកុមារគួរចាប់ផ្តើមផ្តល់អាហារបន្ថែមលើការបៅដោះម្តាយ?
4) ហេតុអ្វីទើបកុមារដែលស្ថិតនៅក្នុងអាយុនេះចាំបាច់ត្រូវបៅដោះម្តាយផង និងផ្តល់អាហារផង?

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (៥នាទី)

ពណ៌នា និងពន្យល់ពីរូបភាព៖

- នេះគឺជារូបភាពម្តាយបំបៅដោះកូន ដោយទឹកដោះតែមួយមុខគត់ដល់អាយុ ៦ខែ។
- ដូចដែលយើងបានរៀននៅក្នុងវីដេអូកាលពីសប្តាហ៍មុន កុមារចាប់ពីអាយុ៦ខែទៅ ត្រូវការអាហារផ្សេងៗទៀត ពីព្រោះទឹកដោះម្តាយតែមួយមុខអាចផ្តល់ថាមពល និងសារជាតិចិញ្ចឹមខ្លះមិនគ្រប់គ្រាន់សម្រាប់ការលូតលាស់ឆាប់រហ័សរបស់កុមារឡើយ។
- ទោះបីជាយ៉ាងណាក៏ដោយ វាជាការសំខាន់ផងដែរដែលម្តាយគួរបន្តបំបៅកូនដោយទឹកដោះម្តាយអោយបានយ៉ាងហោចណាស់អាយុ ២ ឆ្នាំ ព្រោះសារជាតិចិញ្ចឹមនៅក្នុងទឹកដោះម្តាយជួយអោយ ប្រភពគ្រឹះសម្រាប់កុមារក្នុងការរីកលូតលាស់ និងប្រឆាំងជំងឺផ្សេងៗ។

## ៤ បូកសរុប និងសង្ខេបមេរៀន (៥នាទី)

ផ្តល់សារគន្លឹះ៖

- បំបៅដោះកូនរបស់អ្នកតាមចិត្តកុមារ ចង់បន្ថែមពីលើអាហារបន្ថែម។
- បំបៅដោះកូនរបស់អ្នករហូតដល់កុមារអាយុ២ឆ្នាំ ឬលើស។
- ចាប់ផ្តើមផ្តល់អាហារបន្ថែមនៅអាយុ៦ខែ ព្រមទាំងបន្តបំបៅដោះកុមារ។

(ពេលវេលាសរុប ៣០នាទី)

# មេរៀនទី២. ការបន្តបំបៅកូនដោយទឹកដោះម្ដាយ





ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

## បន្តបំបៅដោះកូនរហូតដល់ កូនរបស់អ្នកអាយុ២ឆ្នាំ ឬលើស

# មេរៀនទី៣. អាហារូបត្ថម្ភសម្រាប់ម្តាយ ដែលបំបៅកូនដោយទឹកដោះ

**វត្ថុបំណង៖** រៀបរាប់ពីបរិមាណនិងប្រភេទអាហារដែលម្តាយគួរបរិភោគនៅពេលគាត់កំពុងបំបៅដោះកូន និងវិធានការសុខភាពដទៃទៀតដែលម្តាយបំបៅកូនដោយ ទឹកដោះគួរអនុវត្តដើម្បីសុខភាព។

## ១ បង្ហាញសន្លឹកផ្ទាត់ (៥នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**សន្លឹកផ្ទាត់ទំព័រទី ៤**



## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (១៥នាទី)

សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុលជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) តើអ្នកគិតថារូបភាពនេះនិយាយផ្តោតសំខាន់ពីអ្វី?
3) តើអ្នកផ្សេងៗគិតថាយ៉ាងដូចម្តេចដែរ?

សរសេរចម្លើយនៅលើក្រដាសផ្ទាំងធំ និងពិភាក្សា។

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (១០នាទី)

ពណ៌នា និងពន្យល់ពីរូបភាពនីមួយៗ៖

- រូបភាពនៅខាងស្តាំដែបង្ហាញពីម្តាយ និងកូនរបស់គាត់។
- ស្ត្រីក្រោយសម្រាលនិងស្ត្រីកំពុងបំបៅដោះកូន។
- នៅក្នុងរូបភាពនេះដែរយើងមើលឃើញអាហារផ្សេងៗគ្នាទាំង៣ក្រុមដែលម្តាយគួរបរិភោគអាហារចម្រុះមុខរៀងរាល់ថ្ងៃ៖
  - អាហារថាមពល៖ ដូចជា បាយ ឬ មី នំបញ្ចុក ឬ នំប៉័ង
  - អាហារស្ថាបនា៖ ផលិតផលពីសត្វដូចជា ត្រី មាន់ សាច់ ស៊ុត ថ្លើម សណ្តែក ឬ តៅហ៊ូ
  - អាហារការពារ៖ ផ្លែឈើ និងបន្លែ ជាពិសេសបន្លែស្លឹកពណ៌បៃតង បន្លែពណ៌ទឹកក្រូច (ឧទាហរណ៍ ល្ពៅ ការ៉ុត) និងផ្លែឈើពណ៌លឿង និងទឹកក្រូច ដូចជាល្ហុងទុំ និង ស្វាយទុំ
- ម្តាយគួរបរិភោគអាហារអោយបានបួនដងក្នុងមួយថ្ងៃ និងអាហារក្រៅពេលនៅចន្លោះពេលបាយ ដើម្បីទ្រទ្រង់ដល់ខ្លួនគាត់ និងការលូតលាស់ទារករបស់គាត់ និងជួយអោយមានទឹកដោះចេញគ្រប់គ្រាន់។
- រូបភាពផ្សេងទៀត យើងឃើញបុគ្គលិកមណ្ឌលសុខភាពកំពុងផ្តល់សេវាសុខភាព និងម្តាយដែលបានទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដើម្បីពិនិត្យសុខភាព។
- រូបភាពចុងក្រោយ មានកុមារ និងម្តាយដែលគេងនៅក្នុងមុងជ្រលក់ថ្នាំការពារសត្វល្អិតខាំ។ សកម្មភាពនេះគឺដើម្បីការពារជំងឺគ្រុនចាញ់។

## ៤ បូកសរុប និងសង្ខេបមេរៀន (១០នាទី)

ផ្តល់សារគន្លឹះ៖

- ចូរបរិភោគអាហារអោយបានបួនដងក្នុងមួយថ្ងៃ និងអាហារផ្សេងៗចន្លោះពេលបាយដើម្បីទ្រទ្រង់ដល់ការលូតលាស់ទារករបស់អ្នក និងដើម្បីអោយមានទឹកដោះចេញគ្រប់គ្រាន់។
- ម្តាយគួរទៅមណ្ឌលសុខភាពទៀងទាត់ដើម្បីពិនិត្យសុខភាព។
- នៅមណ្ឌលសុខភាព ម្តាយនឹងទទួលបានគ្រាប់ថ្នាំជីវជាតិអា និងគ្រាប់ថ្នាំជាតិដែក។ បុគ្គលិកមណ្ឌលសុខភាពនឹងពន្យល់ពីពេលណា និងរបៀបលេបថ្នាំទាំងនោះ។
- ប្រសិនបើអ្នករស់នៅក្នុងតំបន់មានជំងឺគ្រុនចាញ់ អ្នក និងកូនរបស់អ្នកត្រូវគេងក្នុងមុងដែលបានជ្រលក់ថ្នាំការពារសត្វល្អិតដើម្បីការពារជំងឺគ្រុនចាញ់។

(ពេលវេលាសរុប ៤០នាទី)




# អាហារូបត្ថម្ភ និងការគាំពារសុខភាពក្នុងពេលបំបៅដោះ

ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# មេរៀនទី៤. ភាពចម្រុះមុខអាហារ៖ អាហារបីក្រុម

**ទត្ថុបំណង៖** រៀបរាប់ពីតួនាទីនៃក្រុមអាហារនីមួយៗក្នុងចំណោមអាហារទាំងបីក្រុម ក្នុងការថែរក្សាសុខភាព និងការរីកលូតលាស់បានល្អសម្រាប់កុមារ។

## ១ បង្ហាញសន្លឹកផ្ទាត់ (១០នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**សន្លឹកផ្ទាត់ទំព័រទី ១០**



## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (១៥នាទី)

សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុលជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) តើមានអ្វីខ្លះក្នុងរង្វង់ទាំងបី? តើអ្នកស្គាល់អាហារទាំងអស់នេះទេ? តើអ្នកតែងតែប្រើប្រាស់អាហារទាំងនេះនៅផ្ទះរបស់អ្នកដែរឬទេ?
3) តើរូបភាពអ្វីខ្លះខាងក្រោមរង្វង់ទាំងនេះ? តើរូបភាពទាំងនេះតំណាងអោយអ្វី?

សរសេរចម្លើយនៅលើក្រដាសផ្ទាំងធំ៖

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (១៥នាទី)

ពណ៌នា និងពន្យល់ពីរូបភាពនីមួយៗ៖

- យើងមើលឃើញគ្រួសារបរិភោគអាហារច្រើនមុខខុសៗគ្នា។
- នៅក្រោមរូបភាពនេះ មានរង្វង់បី ដែលមានអាហារផ្សេងៗគ្នា ហើយវាតំណាងអោយ អាហារបីក្រុម។
  - អាហារថាមពល៖ ដូចជា បាយ គុយទាវ នំប៉ុង ដំឡូងបារាំង ប្រេងឆា ។ល។ អាហារថាមពល ជាធម្មតាបានមកពីរុក្ខជាតិ ប៉ុន្តែក៏បានមកពីសត្វផងដែរ ឧទាហរណ៍ ខ្លាញ់ និងប៉រ។ កុមារក្នុងរូបភាពគឺកំពុងរត់លេង។ ពួកគេមាន ថាមពលច្រើនដែលបានមកពីអាហារថាមពល។
  - អាហារស្ថាបនារាងកាយ៖ ដើម្បីលូតលាស់ និងខ្លាំងក្លា យើងចាំបាច់បរិភាគ អាហារស្ថាបនារាងកាយ ដូចជា សាច់ ត្រី ស៊ុត ថ្លើម សណ្តែក សណ្តែកសៀង និងតៅហ៊ូ។ នៅក្នុងរូបភាពនេះ ក្មេងស្រីម្នាក់ គឺខ្ពស់ជាងក្មេងស្រីម្នាក់ទៀត ហើយរូបភាពតំណាងអោយការលូតលាស់ និងរឹងមាំ។
  - អាហារការពាររាងកាយ៖ ដូចជាបន្លែ ដែលបកសំបក ឆ្អិន កិនម៉ដ្ឋ និងផ្លែឈើដែលមានពណ៌ឆើតដូចជាបៃតងស្រស់ ពណ៌ទឹកក្រូច ពណ៌ក្រហម ឬពណ៌លឿង។ ពណ៌ទាំងអស់នេះបានមកពីប្រភេទខុសៗគ្នានៃវីតាមីនដែលមាននៅក្នុងផ្លែឈើ និងបន្លែ។ ក្នុងរូបភាពនេះ យើងមើលឃើញកុមារមានសុខភាពល្អពីរនាក់ និងវេជ្ជបណ្ឌិត។ កុមារមានសុខភាពល្អព្រោះពួកគេបរិភោគអាហារការពាររាងកាយពីជំងឺផ្សេងៗ។
- វាមិនទាន់គ្រប់គ្រាន់ទេដោយគ្រាន់តែហូបដើម្បីបំពេញក្រពះកុមារ។ យើងចាំបាច់ត្រូវ បញ្ចុកកុមារអាហារចម្រុះមុខចេញពីអាហារទាំងបីក្រុមខុសៗគ្នា។ នេះក៏ដោយសារតែអាហារជួយរាងកាយរបស់យើងខុសៗគ្នា ហើយជួយអោយរាងកាយមានថាមពល និងខ្លាំងក្លា និងការពារពីជំងឺ ព្រមទាំងជួយអោយខួរក្បាល អភិវឌ្ឍន៍ព្រមគ្នាផងដែរ។

## ៤ បូកសរុប និងសង្ខេបមេរៀន (៥នាទី)

ផ្តល់សារគន្លឹះ៖

- ចាប់ពីអាយុ៦ខែ ចូរបញ្ចុកកូនរបស់អ្នកបបរខាប់គ្រប់គ្រឿង ធ្វើពីសាច់ ឬ ត្រី ឬ សណ្តែក ជាមួយនិងបន្លែគ្រប់ពេល។
- បញ្ចុកផ្លែឈើដល់កុមារដូចជា ចេកទុំ ឬ ស្វាយទុំ ឬ ផ្លែឈើទន់ៗដ៏ទៃទៀត ជាអាហារក្រៅពេល(កុមារអាយុ៩ - ២៤ខែ)។
- បន្តបំបៅដោះកូនរបស់អ្នករហូតដល់គាត់ ឬនាងអាយុ២ឆ្នាំ ឬលើស។

(ពេលវេលាសរុប ៤៥នាទី)

# មេរៀនទី៤. ភាពចម្រុះមុខអាហារៈ អាហារបីក្រុម















**អាហារបីក្រុម ៖ ហេតុអ្វីបានជាកូនរបស់អ្នកត្រូវការបរិភោគអាហារចម្រុះមុខ ?**

ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# ចប់លើកទី ១

តើអ្នកមានសំនួរអ្វីទេ ?

អរគុណអ្នកថែទាំកុមារសម្រាប់ការចូលរួម និងរំលឹកពួកគាត់ពីកាលបរិច្ឆេទ និងពេលវេលានៃមេរៀនបន្ទាប់។

# វគ្គបណ្ដុះបណ្ដាល លើកទី ២

## សម្ភារៈគ្រូឧទ្ទេស

### មុនចាប់ផ្ដើមមេរៀនអ្នកគ្រូឧទ្ទេសត្រូវ៖

- រៀបចំមេរៀនដោយការអានសន្លឹកផ្ទាត់ដែលត្រូវបង្រៀន
- សន្លឹកផ្ទាត់
- ក្រដាសផ្ទាំងធំ
- ហ្វឺតសរសេរ
- ស្កុត
- ធុងទឹក
- ចានដែកលាងដៃ
- កន្សែងជូតដៃ
- សាប៊ូលាងដៃ

ប្រភព៖ កម្មវិធីជាតិអាហារូបត្ថម្ភ













ប្រភព៖ កម្មវិធីជាតិអាហារូបត្ថម្ភ

# មេរៀនទី៥. ការរៀបចំអាហារប្រកបដោយអនាម័យ

**ទត្ថុបំណង៖** រៀបរាប់ពីសារៈសំខាន់នៃអនាម័យចំណីអាហារ និងរបៀបធ្វើអោយអាហារមានសុវត្ថិភាព។

## ១ បង្ហាញសន្លឹកផ្ទាត់ (៥នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**សន្លឹកផ្ទាត់ទំព័រទី ១៨**



## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (២០នាទី)

**សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុលជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖**

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?

**សរសេរចម្លើយនៅលើក្រដាសផ្ទាំងធំ/ក្តារខៀន**

2) តើអ្នកធ្លាប់ធ្វើតាមរបៀបដែលអ្នកឃើញក្នុងរូបភាពទាំងនេះដែរឬទេ?

3) តើវាងាយស្រួល ឬក៏លំបាកក្នុងការធ្វើកិច្ចការទាំងនេះ?
តើអ្វីខ្លះដែលងាយស្រួលក្នុងការធ្វើ?
តើអ្វីខ្លះដែលពិបាកក្នុងការធ្វើ?

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (១០នាទី)

### ពណ៌នា និងពន្យល់ពីរូបភាព៖

- ការបរិភោគអាហារ និងទឹកកខ្វក់អាចបណ្តាលអោយកុមារកើតជំងឺផ្សេងៗ ដូចជា ជំងឺរាក គ្រុនពោះវៀន អាសន្នរោគ និងជំងឺរលាកថ្លើម ។ល។
- អ្នកថែទាំកុមារតូចៗត្រូវប្រុងប្រយ័ត្ននៅពេលរៀបចំ និងបញ្ចុកអាហារដល់កូនរបស់ខ្លួន ដើម្បីការពារពីជំងឺផ្សេងៗ។
- រូបភាពទាំងនេះ គឺជាការអនុវត្តន៍អនាម័យល្អ ដើម្បីធានាថាគ្រួសាររបស់អ្នកបរិភោគអាហារមានសុវត្ថិភាព និងរស់នៅស្អាត។

### ពណ៌នា និងពន្យល់ពីរូបភាពនីមួយៗ៖

1. លាងដៃរបស់អ្នកជាមួយទឹកស្អាត និងសាប៊ូ មុនពេលរៀបចំ និងបញ្ចុកអាហារដល់កូន។
2. លាងសម្ភារៈប្រើប្រាស់ជាមួយទឹកស្អាត និងសាប៊ូអោយបានស្អាត ហើយទុកដាក់ក្នុងទូចាន ឬគ្របអោយបានល្អ។
3. គ្របអាហារដែលចម្អិនហើយអោយបានជិតដើម្បីការពាររុយ សត្វល្អិតផ្សេងៗ ធូលី និងមេរោគផ្សេងៗ។
4. ដាំទឹកសម្រាប់ផឹកអោយបានឆ្អិនល្អដើម្បីសម្លាប់មេរោគ។
5. លាងបន្លែ និងផ្លែឈើអោយបានស្អាតមុននឹងចម្អិន ឬបរិភោគ។

## ៤ បូកសរុប និងសង្ខេបមេរៀន (១០នាទី)

### ផ្តល់សារគន្លឹះ៖

- ចូរលាង បន្លែ សាច់ ត្រី ជាមួយទឹកស្អាតអោយបានស្អាត។
- លាងដៃមុនចម្អិន និងមុនពេលបញ្ចុកកុមារ។
- លាងចាន ឆ្នាំង និងផ្រុញជាមួយទឹកស្អាត។
- គ្របអាហារ និងទុកដាក់សម្ភារៈនៅកន្លែងដែលស្អាត។
- ជានិច្ចកាលត្រូវផឹកទឹកឆ្អិន។

(ពេលវេលាសរុប ៤៥នាទី)

# មេរៀនទី៥. ការរៀបចំអាហារប្រកបដោយអនាម័យ



## អនាម័យចំណីអាហារ

ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# មេរៀនទី៦. ការលាងដៃជាមួយទឹកស្អាត និងសាប៊ូ

**វត្ថុបំណង៖** រៀបរាប់និងធ្វើបង្ហាញពីវិធីត្រឹមត្រូវនៃការលាងដៃ។

## ១ បង្ហាញសន្លឹកផ្ទាត់ (៥នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**ផ្ទាំងរូបភាពទី២**



## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (១០នាទី)

**សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុល ជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖**

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) ហេតុអ្វីបានជាយើងចាំបាច់ត្រូវលាងដៃ?
3) តើយើងត្រូវលាងដៃរបស់យើងនៅពេលណាខ្លះ?

**សរសេរចម្លើយនៅលើក្រដាសផ្ទាំងធំ៖**

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (២៥នាទី)

លាងដៃតាមពេលដូចបានរៀបរាប់ខាងលើ នឹងជួយការពារការឆ្លងមេរោគចូលក្នុងអាហារ ឬ ទឹក ដែលធ្វើអោយកូន និងសមាជិកគ្រួសាររបស់អ្នកមានជំងឺផ្សេងៗ។

**ពណ៌នាពីរូបភាព៖**

រូបភាពនេះបង្ហាញពីការលាងដៃត្រឹមត្រូវ ជាមួយទឹកស្អាត និងសាប៊ូ។

**ធ្វើបង្ហាញពីវិធីត្រឹមត្រូវនៃការលាងដៃ។ ទុកអោយអ្នកថែទាំកុមារអនុវត្តការលាងដៃតាមវិធីនេះ។ ស្នើអោយអ្នកថែទាំកុមារ ២ ទៅ៣នាក់ អនុវត្តការធ្វើបង្ហាញពីការលាងដៃ ដល់អ្នកថែទាំកុមារដទៃទៀត៖**

1. ផ្សើមដៃជាមួយទឹក។
2. ដុសដៃនឹងសាប៊ូ រហូតសព្វនិងមានពពុះ។
3. ដុសដៃគ្រប់កន្លែង រយៈពេល ២០វិនាទី (រាប់ពី ១ ដល់ ២០ ឬច្រៀងចម្រៀងមួយបទដែលមានរយៈពេល ២០វិនាទី)៖
   - ក. ដុសបាតដៃ
   - ខ. ដុសខ្នងដៃ
   - គ. ដុសចន្លោះម្រាមដៃ និង
   - ឃ. ដុសក្រោមក្រចកដោយប្រើក្រចកដៃម្ខាងទៀត
   - ង. ដុសក្រចកនឹងបាតដៃម្ខាងទៀត។
4. ក្រោយរយៈពេល២០វិនាទី សម្អាតដៃជាមួយទឹកស្អាតរហូតដល់ជ្រះសាប៊ូ។
5. ជូតសម្ងួតដៃនឹងកន្សែងស្អាត ឬក៏ទុកអោយស្ងួតដោយសារខ្យល់។ កុំជូតដៃនឹងកន្សែង/ក្រណាត់ដែលកខ្វក់។

## ៤ បូកសរុប និងសង្ខេបមេរៀន (៥នាទី)

**ផ្តល់សារគន្លឹះ៖**

- លាងដៃជាមួយទឹកស្អាត និងសាប៊ូមុនពេលរៀបចំ និងបញ្ចុកអាហារ។
- លាងដៃរបស់អ្នក និងកូនរបស់អ្នកជាមួយទឹកស្អាត និងសាប៊ូ មុនពេលបរិភោគអាហារ។
- លាងដៃរបស់អ្នកជាមួយទឹកស្អាត និងសាប៊ូ ក្រោយចេញពីបង្គន់ ឬលាងគូទកូន។

**(ពេលវេលាសរុប ៤៥នាទី)**

# មេរៀនទី៦. ការលាងដៃជាមួយទឹកស្អាត និងសាប៊ូ




ប្រភពៈ យូនីសេហ្វ

# មេរៀនទី៧. របៀបរៀបចំអាហារបន្ថែម៖ វគ្គ ១

**វត្ថុបំណង៖** រៀបរាប់ពីអាហារដែលគេអាចប្រើដើម្បីធ្វើបបរខាប់គ្រប់គ្រឿង។

## ១ បង្ហាញសន្លឹកផ្ទាត់ (៥នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**សន្លឹកផ្ទាត់ទំព័រទី ១២**



## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (២០នាទី)

សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុល ជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) តើអ្នកស្គាល់អាហារណាខ្លះក្នុងរូបភាព?
3) សូមរៀបរាប់ពីរបៀបដែលគេរៀបចំអាហារទាំងនេះ?
4) តើអ្នកធ្លាប់បានរៀបចំអាហារសម្រាប់កូនដូចគ្នា ឬ ខុសគ្នាពីរូបភាពនេះដែរឬទេ?

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (១០នាទី)

ពណ៌នា និងពន្យល់ពីរូបភាពនីមួយៗ៖

- រូបភាពទាំងនេះបង្ហាញអំពីការរៀបចំ និងពាតអាហារផ្សេងៗសម្រាប់កុមារតូចៗ ដូចជា៖ ចេកពាត បបរពាត ស៊ុតផ្នែកក្រហម ដំឡូងផ្ទាពណ៌លឿង និងល្ពៅពាតម៉ដ្ឋ។ អាហារពាតមានសភាព ទន់ប៉ុន្តែមិនស្ងួតទេ។
- រូបភាពនៅខាងឆ្វេងគឺម្តាយកំពុងបំបៅដោះកូន មានន័យថាម្តាយត្រូវផ្តល់ទឹកដោះដល់កូន ព្រមទាំងផ្តល់អាហារបន្ថែមផងដែរ។
- រូបភាពនៅកណ្តាល គឺជាកុមារមានសុខភាពល្អ ព្រោះម្តាយរបស់ពួកគេបញ្ចុក អាហារបន្ថែមដែលមានសារជាតិចិញ្ចឹមដល់ពួកគេ (រូបភាពនៅខាងស្តាំ)។

## ៤ បូកសរុប និងសង្ខេបមេរៀន (៥នាទី)

ផ្តល់សារគន្លឹះ៖

- បញ្ចុកកូនរបស់អ្នកជាមួយអាហារប្រភពមកពីសត្វ ដូចជា ត្រី ឬ សាច់ ឬ ស៊ុត ឬ សណ្តែក រៀងរាល់ថ្ងៃ។
- បញ្ចុកកូនរបស់អ្នកជាមួយបន្លែរៀងរាល់ថ្ងៃ។
- បញ្ចុកកូនរបស់អ្នកជាមួយចានចង្កឹះ និងស្លាបព្រា។

(ពេលវេលាសរុប ៤០នាទី)



## របៀបរៀបចំអាហារបន្ថែមដល់កុមារតូចៗ (វគ្គ ១)

ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# មេរៀនទី៨. របៀបរៀបចំអាហារបន្ថែម៖ វគ្គ ២

**វត្ថុបំណង៖** រៀបរាប់ពីរបៀបចម្អិនបបរខាប់គ្រប់គ្រឿងសម្រាប់កុមារតូចៗ។

## ១ បង្ហាញសន្លឹកផ្ទាត់ (៥នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**សន្លឹកផ្ទាត់ទំព័រទី ១៣**



## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (១៥នាទី)

សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុល ជាមួយពួកគាត់ដោយសួរសំនួរខាងក្រោម៖

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) តើអ្នកអាចរកអាហារទាំងនេះបានដែរឬទេ នៅក្នុងភូមិរបស់អ្នក?
3) តើអ្នកចេះរៀបចំធ្វើបបរខាប់គ្រប់គ្រឿងសម្រាប់កូនរបស់អ្នកដែរឬទេ?

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (៥នាទី)

**ពណ៌នា និងពន្យល់ពីរូបភាពនីមួយៗ៖**

- រូបភាពទាំងនេះបង្ហាញអ្នកថែទាំកុមារ អំពីការរៀបចំធ្វើអាហារបន្ថែមដល់កុមារតូចៗ ដូចជា៖
  - **ត្រី៖** គួរចម្អិនអោយឆ្អិន និងបេះយកឆ្អឹងចេញហើយពាតអោយម៉ដ្ឋ។
  - **បន្លែ៖** គួរចិញ្ច្រាំអោយល្អិត និងចម្អិនអោយឆ្អិនល្អ។
  - **សាច់៖** គួរចិញ្ច្រាំអោយម៉ដ្ឋ និងចម្អិនអោយឆ្អិនល្អ។
- រូបភាពនៅខាងឆ្វេង គឺម្តាយកំពុងបំបៅដោះកូន មានន័យថាម្តាយត្រូវបំបៅទឹកដោះដល់កុមារ មុនផ្តល់អាហារបន្ថែមដល់កុមារតូចៗ។
- រូបភាពកុមារនៅកណ្តាលជាកុមារមានសុខភាពល្អ ព្រោះម្តាយរបស់ពួកគេបញ្ចុក អាហារបន្ថែមដែលមានសារជាតិចិញ្ចឹមគ្រប់គ្រាន់ (ដូចរូបភាពនៅខាងស្តាំ)។

អាហារបន្ថែមល្អគួរមានអាហារចម្រុះមុខលាយបញ្ចូលគ្នា យកចេញពីក្រុម និងប្រភេទអាហារនីមួយៗ៖

**អាហារម្សៅ + អាហារមានជាតិសាច់ ឬ សណ្តែក + បន្លែ + ប្រេងឆា/ខ្លាញ់បន្តិច**

## ៤ បូកសរុប និងសង្ខេបមេរៀន (៥នាទី)

**ផ្តល់សារគន្លឹះ៖**

- បញ្ចុកកូនរបស់អ្នកជាមួយត្រី ឬ សាច់ ឬ ស៊ុត ឬ សណ្តែក រៀងរាល់ថ្ងៃ។
- អាហារបន្ថែមល្អ គួរមានអាហារចម្រុះមុខលាយគ្នាបញ្ចូលគ្នាយកចេញពីអាហារបីក្រុម រួមមាន អាហារម្សៅ អាហារមានជាតិសាច់ ឬ សណ្តែក បន្លែ និងប្រេងឆា/ខ្លាញ់។

(ពេលវេលាសរុប ៣០នាទី)



## របៀបរៀបចំអាហារបន្ថែមដល់កុមារតូចៗ (វគ្គ ២)

ប្រភពៈ កម្មវិធីជាតិអាហារូបត្ថម្ភ

# ចប់លើកទី ២

តើអ្នកមានសំនួរអ្វីទេ ?

អរគុណអ្នកថែទាំកុមារសម្រាប់ការចូលរួម និងរំលឹកពួកគាត់ពីកាលបរិច្ឆេទ និងពេលវេលានៃមេរៀនបន្ទាប់។

# វគ្គបណ្តុះបណ្តាល លើកទី ៣



## សម្ភារៈត្រូវការ

### មុនចាប់ផ្តើមមេរៀនអ្នកត្រូវ៖

- រៀបចំមេរៀនដោយការអានសន្លឹកផ្ទាត់ដែលត្រូវបង្រៀន
- សន្លឹកផ្ទាត់
- ក្រដាសផ្ទាំងធំ
- ហ្វឹតសរសេរ
- ស្កុត
- សម្ភារៈចម្អិន (ចាន ឆ្នាំង កាំបិត ជ្រុញ ចាន ស្លាបព្រា អុស/ធ្យូង ។ល។)
- គ្រឿងផ្សំ




ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ




ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# មេរៀនទី៩. អាហារក្រៅពេល (ផ្លែឈើ)

**វត្ថុបំណង៖** រៀបរាប់ពីការជ្រើសរើស និងរបៀបរៀបចំអាហារក្រៅពេលសមស្របសម្រាប់កុមារ។

## ១ បង្ហាញសន្លឹកផ្ទាត់ (៥នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**ផ្ទាំងរូបភាពទី៣**





លាងចេកទុំជាមួយទឹកស្អាត


បកសំបកចេកពាក់កណ្ដាល


កោសចេកស្រាលៗជាមួយស្លាបព្រា


ពាតចេកឲ្យម៉ដ្ឋ

## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (១៥នាទី)

សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុលជាមួយពួកគាត់ដោយសួរសំនួរខាងក្រោម៖

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) តើអ្នកមានផ្លែឈើទាំងអស់នេះ នៅក្នុងភូមិរបស់អ្នកដែរឬទេ?
3) តើមានអាហារណាខ្លះទៀតដែលល្អសម្រាប់ធ្វើជាអាហារក្រៅពេល?
4) តើអាហារក្រៅពេលណាខ្លះដែលមិនល្អសម្រាប់សុខភាពកូនរបស់អ្នក?

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (១០នាទី)

**ពណ៌នា និងពន្យល់ពីរូបភាពនីមួយៗ៖**

- ចេកទុំ និងល្ហុងទុំ អាចបញ្ចុកកុមារជាអាហារក្រៅពេល នៅចន្លោះអាហារពេល។ ផ្លែឈើផ្សេងទៀតដូចជា ស្វាយទុំ ដំឡូងជ្វា ត្រាវ ឬទឹកសណ្ដែក ក៏អាចបញ្ចុកកុមារជាអាហារក្រៅពេលបានផងដែរ។ ផ្លែឈើស្ថិតនៅក្នុងអាហារការពាររាងកាយ។
- វាជាការប្រសើរបំផុត ការដែលអ្នកថែទាំកុមារមិនផ្ដល់អាហារក្រៅពេលដូចជា៖ ស្ករគ្រាប់ នំកញ្ចប់ ទឹកក្រូចមានហ្គាស ព្រោះវាគ្រាន់តែបំពេញក្រពះកុមារ ប៉ុន្តែវាមិនល្អសម្រាប់សុខភាពទេ។
- រូបភាពទាំងនេះ បង្ហាញពីការរៀបចំផ្លែឈើធ្វើជាអាហារក្រៅពេលសម្រាប់កុមារដែលត្រូវការអាហារនេះ និងពាតអោយម៉ដ្ឋ៖

**បង្ហាញរូបភាពពីការរៀបចំផ្លែចេក៖**

1. លាងចេកទុំជាមួយទឹកស្អាត
2. បកសំបកចេកពាក់កណ្ដាល
3. កោសចេកស្រាលៗជាមួយស្លាបព្រា
4. ពាតចេកអោយម៉ដ្ឋ

ពន្យល់ថា បន្ទាប់ពីកុមារអាយុ៩ខែទៅ កុមារអាចញ៉ាំផ្លែឈើជាដុំតូចៗ ដូចជាចេកទុំ ល្ហុងទុំ និងស្វាយទុំដោយខ្លួនឯងបានហើយ។

## ៤ បូកសរុប និងសន្និដ្ឋានមេរៀន (៥នាទី)

**ផ្ដល់សារគន្លឹះ៖**

- បញ្ចុកកូនរបស់អ្នកផ្លែឈើទុំដូចជាចេក ល្ហុង ស្វាយ ជាអាហារក្រៅពេល។

(ពេលវេលាសរុប ៣៥នាទី)

# មេរៀនទី ៩. អាហារក្រៅពេល (ផ្លែឈើ)





លាងចេកទុំជាមួយទឹកស្អាត


បកសំបកចេកពាក់កណ្តាល


កោសចេកស្រាលៗ
ជាមួយស្លាបព្រា


ពាតចេកឲ្យម៉ដ្ឋ

# មេរៀនទី ១០. អាហារបន្ថែមសមស្របតាមក្រុមអាយុកុមារ

**វត្ថុបំណង៖** រៀបរាប់ពីអនុសាសន៍លើភាពញឹកញាប់ បរិមាណ និងភាពខាប់នៃអាហារបន្ថែម សម្រាប់កុមារដែលមានអាយុខុសៗគ្នា ចាប់ពី ៦ ខែឡើងទៅ។

## ១ បង្ហាញសន្លឹកផ្ទាត់ (១០នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**សន្លឹកផ្ទាត់ទំព័រទី ១៤ ១៥ ១៦ ១៧**






## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (៣០នាទី)

**សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុលជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖**

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) សូមមើលប្រអប់នៅខាងស្តាំ តើគេចង់បង្ហាញពីអ្វី?
3) តើបរិមាណអាហារសម្រាប់ទារកអាយុ ៦ខែប៉ុន្មាន? ៧ទៅ៨ ខែប៉ុន្មាន? ៩ទៅ១១ខែប៉ុន្មាន? ១២ទៅ២៤ខែប៉ុន្មាន?
4) តើក្រុមអាយុកុមារ ៦ខែ ៧ទៅ៨ខែ ៩ទៅ១១ខែ ១២ទៅ២៤ខែ គួរបញ្ចុកអាហារប៉ុន្មានដង?
5) តើមានប្រភេទអាហារណាខ្លះដែលអាចបញ្ចុកទារកនៅអាយុ ៦ខែ ៧ទៅ៨ខែ ៩ទៅ១១ខែ ១២ទៅ២៤ខែ?
6) តើកុមារគួរចាប់ផ្តើមញ៉ាំផ្លែឈើស្រស់ជាអាហារក្រៅពេលនៅអាយុប៉ុន្មាន?

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (១៥នាទី)

**ពណ៌នា និងពន្យល់ពីរូបភាពនីមួយៗ៖**

- រូបភាពទាំងនេះសង្ខេបពីការរៀបចំអាហារបន្ថែម សម្រាប់កុមារប្រើប្រាស់អាហារផ្សេងៗគ្នា
- នៅពេលកូនអ្នកមានអាយុ៦ខែត្រូវការអាហារបន្ថែមលើទឹកដោះម្តាយ។អាហារបន្ថែមដែលត្រូវយកមកផ្តល់អោយកុមារមានបបរខាប់គ្រប់គ្រឿង ហើយត្រូវយកមកអនុវត្តដូចខាងក្រោម៖
  - **នៅពេលកុមារអាយុ ៦ខែ ត្រូវបញ្ចុក៖**
    - បញ្ចុកកូនរបស់អ្នក ២ដងក្នុងមួយថ្ងៃ ព្រឹក ១ ដង ល្ងាច ១ដង។
    - បបរខាប់គ្រប់គ្រឿងកិនអោយម៉ដ្ឋ ២ ទៅ ៣ស្លាបព្រាបាយ ក្នុងមួយពេល។ បៅដោះ ៨ ដងក្នុង ២៤ម៉ោង។
  - **នៅពេលកុមារអាយុ ៧ទៅ៨ខែ ត្រូវបញ្ចុក៖**
    - បញ្ចុកកូនរបស់អ្នក ៣ដងក្នុងមួយថ្ងៃ ព្រឹក ១ដង ថ្ងៃត្រង់ ១ដង ល្ងាច ១ដង។
    - បង្កើនបរិមាណបន្តិចម្តងៗចាប់ពី ៣ស្លាបព្រាបាយ ក្នុងមួយពេលដល់កន្លះចានចង្កឹះ ក្នុងមួយពេល។ បៅដោះ៨ដងក្នុង២៤ម៉ោង។
  - **នៅពេលកុមារអាយុ ៩ទៅ១១ខែ ត្រូវបញ្ចុក៖**
    - បញ្ចុកកូនរបស់អ្នក ៣ដងក្នុងមួយថ្ងៃ ព្រឹក ១ដង ថ្ងៃត្រង់ ១ដង ល្ងាច ១ដង។
    - បង្កើនបរិមាណបន្តិចម្តងៗចាប់ពី កន្លះចានចង្កឹះក្នុងមួយពេល ដល់កាចចានចង្កឹះ ក្នុងមួយពេល។ បៅដោះ៦ដងក្នុង២៤ម៉ោង។
    - ផ្តល់អាហារក្រៅពេលនៅពេលរសៀលមួយដង។ អាហារក្រៅពេលអាចជាអាហារដែល កុមារតូចអាចកាន់បានដោយខ្លួនឯង ដូចជាផ្លែឈើទុំ ល្ហុង ចេក ស្វាយ ដំឡូងផ្វា ត្រាវ ។ល។
  - **នៅពេលកុមារអាយុ ១២ទៅ២៤ខែ ត្រូវបញ្ចុក៖**
    - បញ្ចុកកូនរបស់អ្នក ៣ដងក្នុងមួយថ្ងៃ ព្រឹក ១ដង ថ្ងៃត្រង់ ១ដង ល្ងាច ១ដង។
    - ផ្តល់ ១ចានចង្កឹះពេញ ក្នុងមួយពេល។ បៅដោះ៣ដងក្នុង២៤ម៉ោង។
    - ផ្តល់អាហារក្រៅពេល២ដងមួយដងនៅចន្លោះពេលព្រឹកនិងបាយថ្ងៃត្រង់និងមួយដងទៀតនៅពេលរសៀល។ អាហារក្រៅពេលអាចជាអាហារដែលកុមារតូចៗអាចកាន់បាន ដោយខ្លួនឯង ដូចជាផ្លែឈើទុំ ស្វាយ ល្ហុង ចេក ដំឡូងផ្វា ត្រាវ ។ល។

## ៤ បូកសរុប និងសង្ខេបមេរៀន (៥នាទី)

**ផ្តល់សារគន្លឹះ៖**

- បង្កើនបរិមាណ និងចំនួនដងអាហារបន្ថែមតាមការធំលូតលាស់របស់កុមារ។
- បញ្ចុកកូនរបស់អ្នកនូវផ្លែឈើទុំ ជាអាហារក្រៅពេល ដូចជា ចេក ល្ហុង និងស្វាយ។

(ពេលវេលាសរុប ៦០នាទី)

# មេរៀនទី ១០. អាហារបន្ថែមសមស្របតាមអាយុកុមារ













ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# មេរៀនទី ១១. ការបញ្ចុកអាហារបន្ថែមដោយសកម្ម

**វត្ថុបំណង៖** រៀបរាប់អំពីវិធីក្នុងការបញ្ចុកអាហារបន្ថែមដោយសកម្មដល់កុមារ។

## ១ បង្ហាញសន្លឹកផ្ទាត់ (៥នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**សន្លឹកផ្ទាត់ទំព័រទី ២៦**



## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (១៥នាទី)

សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុលជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) តើសមាជិកគ្រួសារណាខ្លះអាចជួយបញ្ចុកអាហារដល់កុមារបាន?
3) តើមានមធ្យោបាយណាខ្លះដែលមាតាបិតា យាយតា បងប្អូនស្រីប្រុស អាចជួយអោយកុមារហូបអាហារបានច្រើន?

សរសេចម្លើយនៅលើក្រដាសផ្ទាំងធំ

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (១០នាទី)

ពណ៌នា និងពន្យល់ពីរូបភាពនីមួយៗ៖

- រូបភាពទាំងនេះ បង្ហាញពីម្តាយនិងអ្នកថែទាំកុមារបញ្ចុកអាហារដោយសកម្មដល់កូនរបស់គាត់ មានការសរសើរ និងការលើកទឹកចិត្តអោយកុមារញ៉ាំអាហារ។
- សម្រាប់ទារកអាយុ៦ខែ ដែលទើបតែរៀនញ៉ាំអាហារត្រូវដាក់ទារកនៅលើភ្លៅរបស់អ្នក ពេលបញ្ចុកអាហារត្រូវមើលមុខទារក និងអត់ធ្មត់ ហើយព្យាយាមបញ្ចុកអោយបានច្រើនផង សូម្បីតែកុមារខ្ជាក់ចេញក៏ដោយ។
- មាតាបិតា យាយតា បងប្អូនស្រីប្រុសនិងសមាជិកគ្រួសារដទៃទៀតត្រូវតែយកចិត្តទុកដាក់ ដើម្បីអោយកុមារញ៉ាំអាហារបានសារជាតិចិញ្ចឹមបានគ្រប់គ្រាន់។
- ជាធម្មតាកុមារតូចៗញ៉ាំយឺតណាស់ យើងចាំបាច់ត្រូវចំណាយពេលអោយបានច្រើន ពេលបញ្ចុកអាហារដល់កុមារម្តង។
- កុមារតូចៗចូលចិត្តពណ៌ផ្សេងៗ។ ការដាក់អាហារក្នុងចានមានពណ៌ ឬស្លាបព្រាមានពណ៌អាចជួយអោយកុមារញ៉ាំអាហារបានច្រើន។
- ប្រសិនបើ កុមារធំបន្តិចអាចញ៉ាំអាហារដោយមានការលេងកំសាន្តដែលធ្វើអោយកុមារញ៉ាំអាហារបានគ្រប់គ្រាន់។

## ៤ បូកសរុប និងសង្ខេបមេរៀន (៥នាទី)

ផ្តល់សារគន្លឹះ៖

- បង្កើតបរិយាកាសរីករាយពេលបញ្ចុកអាហារកុមារឧទាហរណ៍ទះដៃទាំងពីរ ធ្វើមុខកំប្លែង បើកមាត់របស់អ្នកអោយធំ និយាយពាក្យលើកទឹកចិត្ត។
- បញ្ចុកកុមារយឺតៗ និងអត់ធ្មត់ ព្រមទាំងលើកទឹកចិត្តអោយកុមារញ៉ាំ ហើយសូម កុំបង្ខំកុមារ។
- ធ្វើកំប្លែង និងលេងកំសាន្តដើម្បីលើកទឹកចិត្តកូនរបស់អ្នកញ៉ាំអាហារអស់ពីចាន។

(ពេលវេលាសរុប ៣៥នាទី)

# មេរៀនទី ១១. ការបញ្ចុកអាហារបន្ថែមដោយសកម្ម



## ជំរុញលើកទឹកចិត្តកុមារញ៉ាំឱ្យបានច្រើន

ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# ចម្អិនអាហារបង្ហាញទី ១. ការរៀបចំបបរជាមួយអង្ករ ត្រី និងបន្លែ

**ខត្ថុបំណង៖** ផ្តល់ជំនាញអនុវត្ត និងការជឿជាក់លើខ្លួនឯងដល់អ្នកថែទាំកុមារ ពីការរៀបចំអាហារបន្ថែម ។

## ១ ការចម្អិនអាហារបង្ហាញ និងការអនុវត្ត (៦០នាទី)

**មុខអាហារទី ១៖ បបរអង្ករ ជាមួយ ត្រី និង ស្លឹកម្រុំ**
(សូមមើលឧបសម្ព័ន ១៖ មុខអាហារទី១)

**ចំណាំ៖**

- ត្រូវរៀបចំបបរខាប់គ្រប់គ្រឿងបរិមាណច្រើនទុកជាមុន មុនពេលចាប់ផ្តើមមេរៀន
- សរសេរមុខអាហារនៅលើក្រដាសផ្ទាំងធំ (សូមសរសេរទុកមុន មុនចាប់ផ្តើមមេរៀន)





**ជំហានសកម្មភាព៖**

១) ប្រាប់ពីគោលបំណង៖
២) បង្ហាញរូបភាពសន្លឹកផ្ទាត់ទំព័រទី ១១ និង ១៣
៣) សួរសំនួរខាងក្រោម និងពិភាក្សាជាមួយ អ្នកថែទាំកុមារ៖

- តើអ្នកអាចធ្វើបបរខាប់គ្រប់គ្រឿងនេះនៅផ្ទះបានទេ?
- ប្រសិនបើអ្នកពុំមានគ្រឿងផ្សំមួយ តើអ្នកអាចប្រើប្រាស់អាហារប្រហាក់ប្រហែលដែលមាននៅផ្ទះអ្នក ឬ ទិញបានដែរឬទេ?

៤) ពន្យល់និងសង្ខេប ដល់អ្នកថែទាំកុមារ៖

- វាមានសារៈសំខាន់ខ្លាំងណាស់ ចំពោះការចម្អិនបបរខាប់គ្រប់គ្រឿងសម្រាប់កុមារ។ អ្នកអាចបន្ថែម ត្រី ឬ សាច់ ឬ ស៊ុត ឬ សណ្តែក ឬ តៅហ៊ូ និងបន្លែ (ត្រកួន ផ្ទី ល្ពៅ ឬបន្លែស្រដៀងគ្នាដែលអាចរកបាននៅតាមផ្ទះ)។
- បបរខាប់គ្រប់គ្រឿងគួរតែខាប់ និងមិនអាចហូរធ្លាក់ចេញពីស្លាបព្រានៅពេលកាន់ផ្អៀងស្លាបព្រា។ នេះបញ្ជាក់ថាវាសម្បូរដោយសារជាតិចិញ្ចឹម។ បបរខាប់ជួយអោយកូនរបស់អ្នកលូតលាស់ និងខ្លាំងក្លាប្រាជ្ញាឈ្លាសវៃ។

៥) អាន និងពន្យល់មុខអាហារដល់អ្នកថែទាំកុមារមុនពេលចាប់ផ្តើមចម្អិន
៦) ធ្វើបង្ហាញពីរបៀបរៀបចំអាហារបន្ថែម៖

- បង្ហាញពីការលាងសម្ភារៈ
- បង្ហាញពីការលាងដៃដែលត្រឹមត្រូវ
- បង្ហាញពីការលាងអង្ករ សាច់ បន្លែ និងរបៀបចិញ្ច្រាំ ស្ងោរ ពាត។ល។
- បង្ហាញពីការលាយគ្រឿងផ្សំ និងបរិមាណដើម្បីចម្អិនអោយបានបរិមាណ កន្លះចានចង្កឹះ កាចចានចង្កឹះ និង ពេញចានចង្កឹះ

៧) ជួសអាហារអោយម្តាយ និងអ្នកថែទាំកុមារ ទៅតាមតម្រូវការរបស់កុមារ ហើយអ្នកថែទាំកុមារភ្លក្ស និងវាយតម្លៃ បបរទៅលើ (រសជាតិ ភាពខាប់ ក្លិន ពណ៌ និងបរិមាណ)
៨) អនុវត្តការបញ្ចុកដោយសកម្ម
៩) សួរអ្នកថែទាំកុមារ ប្រសិនបើពួកគាត់មានសំណួរ

## ២ បូកសរុប និងសង្ខេបមេរៀន (១០នាទី)

**ផ្តល់សារគន្លឹះ៖**

- ❖ ត្រី សាច់ ស៊ុត ឬ តៅហ៊ូ គឺជាអាហារដែលអ្នកអាចបន្ថែមទៅក្នុងបបរសម្រាប់កូនរបស់អ្នកបាន។
- ❖ អ្នកថែទាំកុមារគួរចម្អិនអាហារសម្រាប់កូនតូចរបស់គាត់អោយបានឆ្អិនសព្វ ទន់ និងពាតអោយម៉ដ្ឋ។
- ❖ ចម្អិនបបរហូតដល់ខាប់ មិនអាចហូរធ្លាក់ចេញពីស្លាបព្រា។

(ពេលវេលាសរុប ៧០នាទី)

# វគ្គបណ្តុះបណ្តាល លើកទី ៤

## សម្ភារៈគ្រូឧទេស

### មុនចាប់ផ្តើមមេរៀនអ្នកគ្រូឧទេស

- រៀបចំមេរៀនដោយការអានសន្លឹកផ្ទាត់ដែលត្រូវបង្រៀន
- សន្លឹកផ្ទាត់ និងផ្ទាំងរូបភាពរៀបចំសណ្តែកដី និងស៊ុតក្រឡុក
- ក្រដាសផ្ទាំងធំ
- ហ្វឺតសរសេរ
- ស្កុត
- សម្ភារៈចម្អិន (ចាន ឆ្នាំង កាំបិត ជ្រុញ ចាន ស្លាបព្រា អុស/ធ្យូង ។ល។)
- គ្រឿងផ្សំ

ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ













ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# ចម្អិនអាហារបង្ហាញទី ២. ការរៀបចំបបរជាមួយ ដំឡូងជ្វា ត្រាវ សណ្តែកដី និង ស៊ុត

**វត្ថុបំណង៖** ផ្តល់ជំនាញអនុវត្ត និងការជឿជាក់លើខ្លួនឯងដល់អ្នកថែទាំកុមារ ពីការរៀបចំអាហារបន្ថែម ។

## ១ ការចម្អិនអាហារបង្ហាញ និងការអនុវត្ត (១២០នាទី)

**មុខអាហារទី ២៖ បបរដំឡូងជ្វា ជាមួយ សណ្តែកដី និងផ្អី**
(សូមមើលឧបសម្ព័ន ១៖ មុខអាហារទី២)

**មុខអាហារទី ៣៖ បបរត្រាវ ជាមួយ ស៊ុត និងស្ពៃចង្កឹះ**
(សូមមើលឧបសម្ព័ន ១៖ មុខអាហារទី៣)







**ចំណាំ៖**

- ត្រូវរៀបចំបបរខាប់គ្រប់គ្រឿងបរិមាណច្រើនទុកជាមុន មុនពេលចាប់ផ្តើមមេរៀន
- សរសេរមុខអាហារនៅលើក្រដាសផ្ទាំងធំ (សូមសរសេរទុកមុន មុនចាប់ផ្តើមមេរៀន)

**ដំហានសកម្មភាព៖**

១) ស្វាគមន៍
២) ប្រាប់ពីគោលបំណង៖
៣) សុំពេលវេលា (មួយព្រឹក)
៤) បង្ហាញរូបភាពសន្លឹកផ្ទាត់ទំព័រទី ១០ ១១ និង ២៦ និង សួរសំនួរខាងក្រោម៖

- តើអ្នកបានធ្វើបបរខាប់គ្រប់គ្រឿងនេះនៅផ្ទះដែរឬទេ?
- តើអ្នកបានប្រើប្រាស់គ្រឿងផ្សំអ្វីខ្លះដើម្បីធ្វើបបរខាប់គ្រប់គ្រឿង?

ពន្យល់និងសង្ខេប ដល់អ្នកថែទាំកុមារ៖

- វាមានសារៈសំខាន់ខ្លាំងណាស់ចំពោះការចម្អិនបបរខាប់គ្រប់គ្រឿង សម្រាប់កុមារ។ អ្នកអាចបន្ថែម ត្រី ឬ សាច់ ឬ ស៊ុត ឬ សណ្តែកដី ឬ តៅហ៊ូ និងបន្លែ (ត្រកួន ផ្អី ល្ពៅ ឬបន្លែស្រដៀងគ្នាដែលអាចរកបាននៅតាមផ្ទះ)។
- បបរខាប់គ្រប់គ្រឿងគួរតែខាប់ និងមិនអាចហូរធ្លាក់ចេញពីស្លាបព្រានៅពេលកាន់ផ្អៀងស្លាបព្រា។ នេះបញ្ជាក់ថាវាសម្បូរដោយសារជាតិចិញ្ចឹម។ បបរខាប់ជួយអោយកូនរបស់អ្នកលូតលាស់ និងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ។

៥) ជ្រើសរើសអ្នកថែទាំកុមារចំនួនបីក្រុម (ច្រើនបំផុត៣នាក់ក្នុង១ក្រុម) ហើយជ្រើសរើសមេក្រុម
៦) ធ្វើបង្ហាញពីរបៀបរៀបចំអាហារបន្ថែម៖

- អាន និងពន្យល់មុខអាហារដល់អ្នកថែទាំកុមារមុនពេលចាប់ផ្តើមចម្អិន
- បង្ហាញពីការលាងសម្ភារៈ
- បង្ហាញពីការលាងដៃដែលត្រឹមត្រូវ និងអោយអ្នកថែទាំកុមារលាងដៃ
- អោយអ្នកថែទាំកុមារបង្ហាញពីការលាងដំឡូងជ្វា ត្រាវ ស៊ុត បន្លែ និងរបៀបបុកសណ្តែកដី ក្រឡុកស៊ុត ចិញ្ច្រាំ ពត។ល។
- អោយអ្នកថែទាំកុមារបង្ហាញពីការលាយគ្រឿងផ្សំ និងបរិមាណដើម្បីចម្អិនអោយបានបរិមាណ កន្លះចានចង្កឹះ កាចចានចង្កឹះ និង ពេញចានចង្កឹះ

៧) វាយតម្លៃបបរ៖
អោយម្តាយ និងអ្នកថែទាំកុមារដួសអាហារទៅតាមតម្រូវការរបស់កុមារ ហើយអោយអ្នកថែទាំកុមារភ្លក្ស និងវាយតម្លៃ បបរទៅលើ (រសជាតិ ភាពខាប់ ក្លិន ពណ៌ និងបរិមាណ)
៨) អនុវត្តន៍ដួសអាហារតាមអនុសាសន៍ (ក្រុមអាយុ)
៩) អនុវត្តការបញ្ចុកដោយសកម្ម
១០) លាងទុកដាក់
១១) សួរអ្នកថែទាំកុមារ ប្រសិនបើពួកគាត់មានសំណួរ

## ២ បូកសរុប និងសង្ខេបមេរៀន (១០នាទី)

**ផ្តល់សារគន្លឹះ៖**

- ❖ សណ្តែកដី ឬ ស៊ុត គឺជាអាហារដែលអ្នកអាចបន្ថែមទៅក្នុងបបរសម្រាប់កូនរបស់អ្នកបាន។
- ❖ សូមចាំថាពេលបញ្ចុកអាហារ គឺជាអំឡុងពេលសម្រាប់ការរៀន និងស្រលាញ់ ដូច្នេះសូមនិយាយទៅកាន់កុមារ និងត្រូវមើលមុខកុមារ។

**(ពេលវេលាសរុប ១៣០នាទី)**

# វគ្គបណ្តុះបណ្តាល លើកទី ៥

## សម្ភារៈគ្រូឧទ្ទេស

### មុនចាប់ផ្តើមមេរៀនអ្នកគ្រូឧទ្ទេស

- រៀបចំមេរៀនដោយការអានសន្លឹកផ្ទាត់ដែលត្រូវបង្រៀន
- សន្លឹកផ្ទាត់
- ក្រដាសផ្ទាំងធំ
- ហ្វឺតសរសេរ
- ស្កុត
- សម្ភារៈចម្អិន (ចាន ឆ្នាំង កាំបិត ជ្រុញ ចាន ស្លាបព្រា អុស/ធ្យូង ។ល។)
- គ្រឿងផ្សំ













ប្រភព៖ កម្មវិធីជាតិអាហារូបត្ថម្ភ

# ចម្អិនអាហារបង្ហាញទី ៣. ការរៀបចំបបរជាមួយ អង្ករថ្លើមជ្រូក និង សាច់មាន់

**វត្ថុបំណង៖** ផ្តល់ជំនាញអនុវត្ត និងការជឿជាក់លើខ្លួនឯងដល់អ្នកថែទាំកុមារ ពីការរៀបចំអាហារបន្ថែម ។

## ១ ការចម្អិនអាហារបង្ហាញ និងការអនុវត្ត (១២០នាទី)

**មុខអាហារទី ៤៖ បបរអង្ករ ជាមួយ ថ្លើមជ្រូក និងស្លឹកបាស**
(សូមមើលឧបសម្ព័ន ១៖ មុខអាហារទី៤)

**មុខអាហារទី ៥៖ បបរអង្ករ ជាមួយ សាច់មាន់ និងត្រកួន**
(សូមមើលឧបសម្ព័ន ១៖ មុខអាហារទី៥)





**ចំណាំ៖**
- ត្រូវរៀបចំបបរខាប់គ្រប់គ្រឿងបរិមាណច្រើនទុកជាមុន មុនពេលចាប់ផ្តើមមេរៀន
- សរសេរមុខអាហារនៅលើក្រដាសផ្ទាំងធំ (សូមសរសេរទុកមុន មុនចាប់ផ្តើមមេរៀន)

**ជំហានសកម្មភាព៖**

១) ស្វាគមន៍
២) ប្រាប់ពីគោលបំណង៖
៣) សុំពេលវេលា (មួយព្រឹក)
៤) បង្ហាញរូបភាពសន្លឹកផ្ទាត់ទំព័រទី ១០ ១១ និង ២៦ និង សួរសំនួរខាងក្រោម៖
- តើអ្នកបានធ្វើបបរខាប់គ្រប់គ្រឿងនេះនៅផ្ទះដែរឬទេ?
- តើអ្នកបានប្រើប្រាស់គ្រឿងផ្សំអ្វីខ្លះដើម្បីធ្វើបបរខាប់គ្រប់គ្រឿង?

ពន្យល់និងសង្ខេប ដល់អ្នកថែទាំកុមារ៖
- វាមានសារៈសំខាន់ខ្លាំងណាស់ចំពោះការចម្អិនបបរខាប់គ្រប់គ្រឿង សម្រាប់កុមារ។ អ្នកអាចបន្ថែម ត្រី ឬ សាច់ ឬ ស៊ុត ឬ សណ្តែកដី ឬ តៅហ៊ូ និង បន្លែ (ត្រកួន ផ្ទី ល្ពៅ ឬបន្លែស្រដៀងគ្នាដែលអាចរកបាននៅតាមផ្ទះ)។
- បបរខាប់គ្រប់គ្រឿងគួរតែខាប់ និងមិនអាចហូរធ្លាក់ចេញពីស្លាបព្រានៅពេលកាន់ផ្អៀងស្លាបព្រា។ នេះបញ្ជាក់ថាវាសម្បូរដោយសារជាតិចិញ្ចឹម។ បបរខាប់ជួយអោយកូនរបស់អ្នកលូតលាស់ និងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ។

៥) ជ្រើសរើសអ្នកថែទាំកុមារចំនួនបីក្រុម (ច្រើនបំផុត៣នាក់ក្នុង១ក្រុម) ហើយជ្រើសរើសមេក្រុម
៦) ធ្វើបង្ហាញពីរបៀបរៀបចំអាហារបន្ថែម៖
- អាន និងពន្យល់មុខអាហារដល់អ្នកថែទាំកុមារមុនពេលចាប់ផ្តើមចម្អិន
- បង្ហាញពីការលាងសម្ភារៈ
- បង្ហាញពីការលាងដៃដែលត្រឹមត្រូវ និងអោយអ្នកថែទាំកុមារលាងដៃ
- អោយអ្នកថែទាំកុមារបង្ហាញពីការលាងអង្ករ សាច់ បន្លែ និងរបៀបចិញ្ច្រាំ ៣ត។ល។
- អោយអ្នកថែទាំកុមារបង្ហាញពីការលាយគ្រឿងផ្សំ និងបរិមាណដើម្បីចម្អិនអោយបានបរិមាណកន្លះចានចង្កឹះ កាចចានចង្កឹះ និង ពេញចានចង្កឹះ

៧) វាយតម្លៃបបរ៖
អោយម្តាយ និងអ្នកថែទាំកុមារជ្រួសអាហារ ទៅតាមតម្រូវការរបស់កុមារ ហើយ អោយអ្នកថែទាំកុមារភ្លក្ស និងវាយតម្លៃ បបរទៅលើ (រសជាតិ ភាពខាប់ ក្លិន ពណ៌ និងបរិមាណ)
៨) អនុវត្តន៍ជួសអាហារតាមអនុសាសន៍ (ក្រុមអាយុ)
៩) អនុវត្តការបញ្ចុកដោយសកម្ម
១០) លាងទុកដាក់
១១) សួរអ្នកថែទាំកុមារ ប្រសិនបើពួកគាត់មានសំណួរ

## ២ បូកសរុប និងសង្ខេបមេរៀន (១០នាទី)

**ផ្តល់សារគន្លឹះ៖**

❖ អាហារមានប្រភពមកពីសត្វដូចជា សាច់មាន់ សាច់ ត្រី និងស៊ុត ជួយកុមារឡើងទម្ងន់ កំលាំងមាំមួន និងរហ័សរហួន។

❖ អាហារមានប្រភពមកពីសត្វ មានសារៈសំខាន់ណាស់ដើម្បីអោយកុមារមានប្រាជ្ញាឈ្លាសវៃ និងរៀនពូកែ។

**(ពេលវេលាសរុប ១៣០នាទី)**

# វគ្គបណ្ដុះបណ្ដាល លើកទី ៦

## សម្ភារៈគ្រូឧទ្ទេស

### មុនចាប់ផ្ដើមមេរៀនអ្នកគ្រូឧទ្ទេស

- រៀបចំមេរៀនដោយការអានសន្លឹកផ្ទាត់ដែលត្រូវបង្រៀន
- សន្លឹកផ្ទាត់
- ក្រដាសផ្ទាំងធំ
- ហ្វឺតសរសេរ
- ស្កុត
- សម្ភារៈចម្អិន (ចាន ឆ្នាំង កាំបិត ជ្រុញ ចាន ស្លាបព្រា អុស/ធ្យូង ។ល។)
- គ្រឿងផ្សំ












ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# មេរៀនទី ១២. ការចិញ្ចឹមកុមារក្នុងពេលឈឺ អាយុចាប់ពី ៦ ខែ

**វត្ថុបំណង៖** រៀបរាប់ពីការផ្តល់អាហារសមស្របក្នុងពេលកុមារមានជំងឺ និងក្រោយពេលជើបពីឈឺ។

## ១ បង្ហាញសន្លឹកផ្ទាត់ (៥នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**សន្លឹកផ្ទាត់ទំព័រទី ២៥**



## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (១៥នាទី)

សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុលជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) តើអ្នកដទៃទៀតគិតដូចម្តេចដែរ?
3) តើកុមារជារឿយៗធ្លាប់មានជំងឺអ្វីខ្លះ?

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (១០នាទី)

**ពណ៌នា និងពន្យល់ពីរូបភាពនីមួយៗ៖**

- រូបភាពនៅខាងស្តាំដៃនេះ បង្ហាញពីកុមារឈឺ/មានជំងឺ
- រូបភាពទី១ កុមារមានជំងឺរាក ហើយត្រូវការបង្គ្រប់ជាតិទឹកដោយអូ៉រ៉ាលីត្រ។ អ្នកនឹងទទួលបានទឹកអូ៉រ៉ាលីត្រ នៅពេលម្តាយនាំកូនទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ព្រមទាំងទទួល បានការណែនាំពីការប្រើប្រាស់វាទៀតផង។
- រូបភាពបន្ទាប់ គឺកុមារកំពុងយំដោយសារក្តៅខ្លួន និងរូបភាពមួយទៀតកុមារកំពុងយំផង ក្អួតផង។
- ជំងឺរាក និងក្អួតអាចធ្វើអោយកុមារបាត់បង់ជាតិទឹក និងអាហារដែលកុមារបានញ៉ាំ។ កុមារអាចនឹងខ្សោះជាតិទឹក ដោយសារតែរាងកាយមិនមានជាតិទឹកគ្រប់គ្រាន់នៅខាងក្នុងខ្លួន។ កុមារក៏អាចស្រកទម្ងន់ផងដែរ។

## ៤ បូកសរុប និងសង្ខេបមេរៀន (៥នាទី)

**ផ្តល់សារគន្លឹះ៖**

- ប្រសិនបើកុមារមានជំងឺរាក ឬ ក្អួត សូមស្វែងរកការព្យាបាលនៅមណ្ឌលសុខភាពដែលនៅជិតបំផុត ដើម្បីទទួលបានទឹកអូ៉រ៉ាលីត្រ ព្រមទាំងការណែនាំក្នុងការប្រើប្រាស់វា។
- អំឡុងពេលឈឺសូមផ្តល់ជាតិទឹករួមទាំងអាហារ៖ ទឹកដោះម្តាយ បបរខាប់គ្រប់គ្រឿង ទឹកដូង និងទឹកឆ្អិនអោយបានញឹកញាប់។
- ដោយសារតែកុមារមានជំងឺ អ្នកថែទាំកុមារចាំបាច់ត្រូវបញ្ចុកអាហារដល់កូនដោយអត់ធ្មត់ និងលើកទឹកចិត្តអោយកុមារញ៉ាំ តាមរយៈការនិយាយជាមួយកូន និងជួយកូនអោយញ៉ាំអាហារបានច្រើន។

# មេរៀនទី ១២. ការចិញ្ចឹមកុមារក្នុងពេលឈឺអាយុចាប់ពី ៦ ខែ




## ការចិញ្ចឹមកុមារក្នុងពេលឈឺ អាយុចាប់ពី ៦ ខែ

ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# មេរៀនទី ១៣. រៀបរៀបចំអាហារបន្ថែម ដោយយកចេញពីអាហារប្រចាំថ្ងៃរបស់គ្រួសារ

**ទត្ថុបំណង៖** រៀបរាប់ពីវិធីរបៀបរៀបចំអាហារបន្ថែម ដោយយកចេញពីអាហារគ្រួសារ។

## ១ បង្ហាញសន្លឹកផ្ទាត់ (៥នាទី)

បង្ហាញរូបភាពទៅអ្នកថែទាំកុមារ៖

**សន្លឹកផ្ទាត់ទំព័រទី ១៩**



## ២ សួរ និងពិភាក្សាជាមួយអ្នកថែទាំកុមារ (១៥នាទី)

**សួរអ្នកថែទាំកុមារអំពីរូបភាព និងពិភាក្សាអោយបានផុសផុលជាមួយពួកគាត់ ដោយសួរសំនួរខាងក្រោម៖**

1) តើរូបភាពទាំងនេះ ប្រាប់អ្នកអំពីអ្វីខ្លះ?
2) តើអ្នកថែទាំកុមាររៀបចំអាហារបន្ថែមសម្រាប់កុមារយ៉ាងដូចម្តេច?
3) តើអ្នកថែទាំកុមារធ្វើអាហារបន្ថែមយ៉ាងដូចម្តេចពីអាហារគ្រួសារសម្រាប់កុមារអាយុពីប៉ុន្មានខែទៅ?

## ៣ ពន្យល់ទៅអ្នកថែទាំកុមារ (១០នាទី)

**ពណ៌នា និងពន្យល់ពីរូបភាពនីមួយៗ៖**

- រូបភាពនៅខាងឆ្វេង បង្ហាញពីការរៀបចំអាហារសម្រាប់គ្រួសារដោយប្រើប្រាស់អាហារចម្រុះមុខ។
- អាហារគ្រួសារ អាចរៀបចំជាបបរខាប់គ្រប់គ្រឿងបញ្ចុកកុមារចាប់ពីអាយុ ៩ខែឡើងទៅ។
- រូបភាពបន្ទាប់អ្នកថែទាំកុមារ បានប្រើប្រាស់ស្លាបព្រាដើម្បីពាតអាហារគ្រួសារនៅលើចានធ្វើជាបបរខាប់។
- អាហារគ្រួសារគួរកិន និងពាតអោយម៉ដ្ឋ ទន់ ទៅជាបបរខាប់គ្រប់គ្រឿង។
- បបរខាប់នោះអាចយកមកបញ្ចុកកុមារបានមិនមានបញ្ហាទេ។
- បន្តបំបៅដោះម្តាយតាមចិត្តកុមារចង់ ហើយគួរបំបៅដោះម្តាយយ៉ាងហោចណាស់រហូតដល់កូនអាយុ ២ឆ្នាំ។

## ៤ បូកសរុប និងសង្ខេបមេរៀន (១០នាទី)

**ផ្តល់សារគន្លឹះ៖**

- កុមារចាប់ពីអាយុ ៩ខែឡើងទៅ អាចអោយអាហារកិនម៉ដ្ឋដែលយកពីអាហារ គ្រួសារ បន្ថែមពីលើការបំបៅទឹកដោះម្តាយ។
- ការធ្វើអាហារបន្ថែម ដែលយកចេញពីអាហារគ្រួសារត្រូវតែមានលក្ខណៈទន់ជ្រាយ ម៉ដ្ឋ ប្រហាក់ប្រហែលនឹងបបរខាប់គ្រប់គ្រឿងរបស់កុមារដែរ។ បញ្ចុកកុមារដោយប្រើប្រាស់ចានដាច់ដោយឡែក។
- បញ្ចុកកុមារនូវអាហារម៉ដ្ឋ និងផុយ ដូចជា ផ្លែឈើទុំធ្វើជាអាហារក្រៅពេល។

**(ពេលវេលាសរុប ៤០នាទី)**



របៀបរៀបចំអាហារសម្រាប់កុមារ ដោយយកចេញពីអាហារប្រចាំថ្ងៃរបស់គ្រួសារ

ប្រភព: កម្មវិធីជាតិអាហារូបត្ថម្ភ

# ចម្អិនអាហារបង្ហាញទី ៤. ការរៀបចំបបរ ដោយយកចេញពីអាហារគ្រួសារ

**ចំណុចបំណង៖** ផ្តល់ជំនាញអនុវត្ត និងការជឿជាក់លើខ្លួនឯងដល់អ្នកថែទាំកុមារ ពីការរៀបចំអាហារបន្ថែម ។

## ១ ការចម្អិនអាហារបង្ហាញ និងការអនុវត្ត (១២០នាទី)

### មុខអាហារទី ៦៖ បាយជាមួយសម្លប្រហើរ សាច់ត្រី

(សូមមើលឧបសម្ព័ន ១៖ មុខអាហារទី៦)







**ចំណាំ៖**

- ត្រូវរៀបចំសម្លប្រហើរ និងដាំបាយទុកជាមុន មុនពេលចាប់ផ្តើមមេរៀន
- សរសេរមុខអាហារនៅលើក្រដាសផ្ទាំងធំ (សូមសរសេរទុកមុន មុនចាប់ផ្តើមមេរៀន)

**ជំហានសកម្មភាព៖**

១) ស្វាគមន៍

២) ប្រាប់ពីគោលបំណង៖

៣) សុំពេលវេលា (មួយព្រឹក)

៤) បង្ហាញរូបភាពសន្លឹកផ្ទាត់ទំព័រទី ១០ ១៩ និង ២៦ និង សួរសំនួរខាងក្រោម៖

- តើធ្លាប់បានធ្វើបបរខាប់គ្រប់គ្រឿង យកចេញពីអាហារគ្រួសារនៅផ្ទះដែរឬទេ?
- តើអ្នកបានលាយគ្រឿង ផ្សំអ្វីខ្លះដើម្បីធ្វើអោយបានបបរខាប់គ្រប់គ្រឿងនេះ?

ពន្យល់និងសង្ខេប ដល់អ្នកថែទាំកុមារ៖

- មុខអាហារដែលយើងទើបតែបានចម្អិនមានផ្សំឡើងពី ត្រី បន្លែ ហើយវាមានសារជាតិចិញ្ចឹមល្អសម្រាប់គ្រួសាររបស់អ្នក និងជាពិសេសសម្រាប់កូន របស់អ្នក៖
- បាយស្ថិតនៅក្នុងអាហារថាមពល
- ត្រីស្ថិតនៅក្នុងអាហារស្ថាបនា
- បន្លែស្លឹកពណ៌បៃតង ល្ពៅ ស្ថិតនៅក្នុងអាហារការពាររាងកាយ

៥) ជ្រើសរើសអ្នកថែទាំកុមារចំនួនបីក្រុម (ច្រើនបំផុត៣នាក់ក្នុង ១ ក្រុម) ហើយជ្រើសរើសមេក្រុម

៦) ធ្វើបង្ហាញពីរបៀបរៀបចំអាហារ៖

- បង្ហាញពីការលាងដៃដែលត្រឹមត្រូវ និងអោយអ្នកថែទាំកុមារលាងដៃ
- បង្ហាញពីការលាយគ្រឿងផ្សំ និងការរៀបចំ

៧) វាយតម្លៃបបរចេញពីអាហារគ្រួសារ៖

អោយអ្នកថែទាំកុមារដួសអាហារដើម្បីរៀបចំអោយបានបរិមាណកាចចានចង្កឹះនិងពេញចានចង្កឹះទៅតាមតម្រូវការរបស់កុមារហើយអោយអ្នកថែទាំកុមារភ្លក្ស និងវាយតម្លៃ បបរទៅលើ (រសជាតិ ភាពខាប់ ក្លិន ពណ៌ និងបរិមាណ)

៨) អនុវត្តន៍រៀបចំអាហារតាមអនុសាសន៍ (ក្រុមអាយុ)

៩) អនុវត្តការបញ្ចុកដោយសកម្ម

១០) លាងទុកដាក់

១១) សួរអ្នកថែទាំកុមារ ប្រសិនបើពួកគាត់មានសំណួរ

## ២ បូកសរុប និងសង្ខេបមេរៀន (១០នាទី)

**ផ្តល់សារគន្លឹះ៖**

- ❖ កុមារចាប់ពីអាយុ ៩ខែឡើង ទៅអាចអោយអាហារកិនម៉ដ្ឋដែលយកពីអាហារ គ្រួសារ បន្ថែមពីលើការបំបៅទឹកដោះម្តាយ។
- ❖ បញ្ចុកកូនរបស់អ្នកអាហារមានប្រភពពីសត្វ ដូចជា ត្រី សាច់ ឬស៊ុតរៀងរាល់ថ្ងៃ។
- ❖ បញ្ចុកកូនរបស់អ្នក បន្លែរៀងរាល់ថ្ងៃ។
- ❖ បញ្ចុកកុមារដោយប្រើប្រាស់ចាននិងស្លាបព្រា ដាច់ដោយឡែក។

អរគុណទៅដល់អ្នកថែទាំកុមារទាំងអស់ចំពោះការចូលរួមរបស់ពួកគាត់។ សូមប្រាប់ពួកគាត់អោយបានដឹងថាការជួបគ្នាលើកក្រោយ គឺជាវគ្គបញ្ចប់នៃការអប់រំ។

**(ពេលវេលាសរុប ១៣០នាទី)**

# វគ្គបណ្តុះបណ្តាល លើកទី ៧

## សម្ភារៈត្រូវការ

### មុនចាប់ផ្តើមមេរៀនអ្នកត្រូវ៖

- រៀបចំមេរៀនដោយការអានសន្លឹកផ្ទាត់ដែលត្រូវបង្រៀន
- ទូរទស្សន៍ និងវីដេអូបបរខាប់គ្រប់គ្រឿង
- សន្លឹកផ្ទាត់
- ក្រដាសផ្ទាំងធំ
- ហ្វឺតសរសេរ
- ស្កុត

# មេរៀនទី ១៤. ការរំលឹកសារគន្លឹះ

**ខត្តុបំណង៖** ដើម្បីរំលឹកពីសារគន្លឹះដែលបានបណ្តុះបណ្តាល។

## ១ ពន្យល់ពីមេរៀនរំលឹកដល់អ្នកថែទាំកុមារ (៥នាទី)

**ពន្យល់ទៅអ្នកចូលរួមថា៖ មេរៀននេះគឺរំលឹកពីមេរៀនទាំងអស់ដែលបានឆ្លងកាត់រហូតមកដល់ពេលនេះ**

ថ្ងៃនេះយើងនឹងមើលសារឡើងវិញគ្រប់មេរៀនទាំងអស់ ដែលយើងបានចូលរួមអស់រយៈពេលច្រើនសប្តាហ៍។

## ២ បង្ហាញ សួរ និងពិភាក្សា (៤៥នាទី)

**ក. ណែនាំពីវីដេអូដែលនឹងបញ្ចាំងសម្រាប់ពួកគាត់**

ដើម្បីចាប់ផ្តើម យើងនឹងទស្សនាវីដេអូស្តីពីការផ្តល់អាហារបន្ថែម ដែលយើងបានមើលនៅមេរៀន ទី១ ។ ខ្ញុំសុំអោយអ្នកស្តាប់ដោយយកចិត្តទុកដាក់ ដោយសារតែវា គឺជាការសង្ខេបមេរៀនពីអ្វីដែលយើងបានរៀនកន្លងមក។

**ខ. បន្ទាប់ពីការបញ្ចាំងវីដេអូ សូមបង្ហាញរូបភាពដែលបានពិភាក្សាកន្លងមក និងសួរ សំនួរ។ អោយអ្នកថែទាំកុមារឆ្លើយសំនួរ។ ផ្តល់ចម្លើយដល់ពួកគាត់នៅចុងបញ្ចប់។**

ឥឡូវនេះ ខ្ញុំនឹងបង្ហាញអ្នកនូវរូបភាព ដែលយើងបានពិភាក្សារួច និងសួរសំនួរខ្លះៗ។ ប្រសិនបើអ្នកដឹងចម្លើយ សូមនិយាយខ្លាំងៗ។ អ្នកអាចជួយគ្នាទៅវិញទៅមកបាន។

**មេរៀនទី ១.២. ការរៀបចំអាហារប្រកបដោយអនាម័យ**

សំនួរ៖ តើការអនុវត្តអនាម័យដែលល្អណាខ្លះ ដែលអាចជួយអោយអាហារបរិភោគ ដោយគ្រួសារមានសុវត្ថិភាព និងស្អាត?

ចម្លើយ៖

- លាងដៃ
- ទុកដាក់ចាន និងសម្ភារ:
- គ្របអាហារ
- ដាំទឹក
- លាងចាន
- លាងបន្លែ និងផ្លែឈើ

សំនួរ: តើអ្នកថែទាំកុមារគួរធ្វើអ្វីមុនពេលគាត់បញ្ចុកអាហារកូន?

ចម្លើយ៖

លាងដៃរបស់ពួកគាត់

**មេរៀនទី ២.២. ភាពចម្រុះមុខអាហារ ៖ អាហារបីក្រុម**

សំនួរ: តើអាហារបែបណាល្អសម្រាប់កុមារញុំា?

ចម្លើយ៖

- **អាហារថាមពល៖** អង្ករ មី នំប៉័ង ដំឡូង ប្រេងឆា
- **អាហារស្ថាបនា៖** សាច់ ត្រី ស៊ុត ថ្លើម សណ្តែក សណ្តែកសៀង តៅហ៊ូ
- **អាហារការពាររាងកាយ៖** បន្លែចិតសំបក ផ្លិន និងពាត និងផ្លែឈើ ដែលមានពណ៌ស្រស់ ដូចជា បៃតង ទឹកក្រូច ក្រហម ឬ ពណ៌លឿង

សំនួរ៖ តើអាហារណាខ្លះ ដែលអាចប្រើប្រាស់ក្នុងការធ្វើបបរខាប់គ្រប់គ្រឿង?

ចម្លើយ៖

បន្លែស្លឹកពណ៌បៃតងចាស់ ល្ពៅ ដំឡូងផ្វា ប្រេងឆា ស៊ុត ត្រី សាច់ សណ្តែកដីសណ្តែក តៅហ៊ូ

**មេរៀនទី ២.៣. អាហារូបត្ថម្ភសម្រាប់ម្តាយដែលបំបៅកូនដោយទឹកដោះ**

សំនួរ៖ តើម្តាយកំពុងបំបៅដោះគួរបរិភោគអាហារបែបណា?

ចម្លើយ៖

ម្តាយកំពុងបំបៅដោះកូនគួរហូបអាហារបួនដងក្នុងមួយថ្ងៃ ដើម្បីមានសុខភាពល្អ និងបង្កើនទឹកដោះសម្រាប់កូនរបស់គាត់។

**មេរៀន ៣. ២. រៀបរៀបចំអាហារបន្ថែម ៖ វគ្គ ២**

សំនួរ៖ តើអាហារសម្រាប់កុមារគួររៀបចំរបៀបណា?

ចម្លើយ៖

អាហារបន្ថែមសម្រាប់កូនរបស់អ្នកគួរចម្អិនអោយឆ្អិនល្អ ចិញ្ច្រាំម៉ដ្ឋ ឬពាត និងទន់។

សំនួរ៖ តើអាហារបន្ថែមដែលល្អគួរមានអ្វីខ្លះ?

ចម្លើយ៖

អាហារបន្ថែមដែលល្អ គួរផ្សំឡើងយ៉ាងហោចណាស់មានអាហារមួយមុខពីអាហារម្សៅ អាហារមានជាតិសាច់ បន្លែ និងប្រេងឆា/ខ្លាញ់

**មេរៀនទី ៤.៣. ការបញ្ចុកអាហារបន្ថែមដោយសកម្ម**

សំនួរ៖ តើអ្នកអាចប្រាប់ខ្ញុំពីវិធីលើកទឹកចិត្តកូនរបស់អ្នកអោយញុំាអាហារបានទេ?

ចម្លើយ៖

បញ្ចុកយឺតៗ និងដោយអត់ធ្មត់ និយាយទៅកាន់កូនពេលកំពុងបញ្ចុក និងមើលមុខកុមារ ទះដៃរបស់អ្នក ធ្វើមុខកំប្លែង ធ្វើកាយវិការហាមាត់អោយធំៗ និយាយពាក្យសរសើរ។

**មេរៀនទី ៥. ១. អាហារបន្ថែមសមស្របតាមអាយុកុមារ**

សំនួរ៖ តើនៅពេលណាម្តាយកុមារ គួរចាប់ផ្តើមផ្តល់អាហារបន្ថែមដល់កូនរបស់គាត់?

ចម្លើយ៖

នៅអាយុ ៦ខែ

សំនួរ៖ តើម្តាយគួរផ្តល់ត្រឹមតែអាហារបន្ថែមដល់កូនរបស់គាត់ទេឬ? គ្មានអ្វីផ្សេងទៀតទេឬ?

ចម្លើយ៖

ទេ។ ម្តាយគួរបន្តបំបៅដោះកូន ខណៈកំពុងផ្តល់អាហារបន្ថែម រហូតដល់កូនអាយុ២ឆ្នាំ ឬលើស។

សំនួរ៖ នៅពេលមួយ កូនរបស់អ្នកលូតលាស់។ តើអ្នកគួរបញ្ចុកកូនរបស់អ្នកដោយរបៀបណា?

ចម្លើយ៖

បរិមាណអាហារបន្ថែមសម្រាប់កូនរបស់អ្នក គួរបង្កើនបរិមាណបន្តិចម្តងៗតាមអាយុរបស់កុមារ។

សំនួរ៖ តើបបរគួរមានសណ្ឋានបែបណា?

ចម្លើយ៖

បបរគួរតែខាប់ ហើយមិនអាចហូរធ្លាក់ចេញពីស្លាបព្រានៅពេលកាន់ ឬផ្អៀងស្លាបព្រា។ នេះបញ្ជាក់ថាវាសម្បូរដោយសារជាតិចិញ្ចឹម។ បបរខាប់ជួយអោយកូនរបស់អ្នកលូតលាស់ និងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ។

**មេរៀនទី ៦.២. ការចិញ្ចឹមកុមារក្នុងពេលឈឺអាយុចាប់ពី៦ខែ**

សំនួរ៖ តើអ្នកគួរបញ្ចុកកុមារឈឺរបៀបណា?

ចម្លើយ៖

បំបៅដោះអោយបានញឹកញាប់ជាងមុន

ផ្តល់អាហារច្រើនជាងមុន៖

- បញ្ចុកបបរខាប់គ្រប់គ្រឿងអោយបានញឹកញាប់ជាងមុនផ្តល់ជាតិទឹកច្រើនជាងមុន៖ ទឹកដូង ទឹកឆ្អិន

## ៣ ថ្លែងអំណរគុណដល់ម្តាយៗ និងអ្នកថែទាំកុមារ (១០នាទី)

ថ្លែងអំណរគុណដល់ការចូលរួមរបស់ម្តាយៗ និងអ្នកថែទាំកុមារទាំងអស់នៅក្នុងវគ្គ។ ខ្ញុំសង្ឃឹមថាម្នាក់ៗសប្បាយចិត្តជាមួយអ្វីដែលបានរៀន និងមានទំនុកចិត្តក្នុងការអនុវត្តពីអ្វីដែលអ្នកបានរៀននៅក្នុងវគ្គនេះ។

ឥឡូវយើងនឹងបន្តកម្មវិធី ឈានទៅដល់ការចែកប័ណ្ណសរសើរបញ្ចប់វគ្គដល់ម្តាយៗ និងអ្នកថែទាំកុមារទាំងអស់គ្នា។

(ពេលវេលាសរុប ៦០នាទី)

# មេរៀនទី ១៥. ពិធីទទួលប័ណ្ណសរសើរ

នៅក្នុងពិធីទទួលប័ណ្ណសរសើរ យើងនឹងមានការចែករំលែកចំណេះដឹង និងការចែកប័ណ្ណសរសើរទៅដល់អ្នកថែទាំកុមារទាំងអស់។ អ្នកថែទាំកុមារទាំងអស់ ព្រមទាំងគ្រួសាររបស់ពួកគេគឺត្រូវបានស្វាគមន៍អោយចូលរួម ព្រមទាំងមេភូមិ មេឃុំ និងបុគ្គលិកសុខាភិបាល។

## ១ សួរទៅអ្នកថែទាំកុមារ (៣០នាទី)

**សួរអ្នកថែទាំកុមារដើម្បីអោយគាត់ចែករំលែកចំណេះដឹងទៅកាន់អ្នកចូលរួមទាំងអស់៖**

- តើមានអ្នកថែទាំកុមារណាអាចចូលរួមចែករំលែកទៅកាន់អ្នកចូលរួមទាំងអស់ពីអ្វីដែលគាត់បានរៀន?

**សួរអ្នកចូលរួមទាំងអស់ដើម្បីចែករំលែកចំណេះដឹងថ្មីរបស់ពួកគាត់៖**

- តើមានអ្នកណាចង់សួរសំនួរ ឬផ្តល់យោបល់ត្រឡប់ឬទេ?

## ២ ចែកប័ណ្ណសរសើរ (៣០នាទី)

(ពេលវេលាសរុប ៦០នាទី)

# ឧបសម្ព័ន្ធ១៖ បញ្ជីមុខអាហារសម្រាប់ការចម្អិនអាហារបង្ហាញ

## មុខអាហារទី ១៖
### បបរអង្ករជាមួយ ត្រី និង ស្លឹកម្រុំ

| គ្រឿងផ្សំ | ១០ចានចង្កឹះពេញ |
|---|---|
| អង្ករ | ២០ ស្លាបព្រាបាយ |
| ទឹក | ៨ ចានចង្កឹះ |
| សាច់ត្រីពាតម៉ដ្ឋ | ២០ ស្លាបព្រាបាយ |
| ស្លឹកម្រុំចិញ្ច្រាំម៉ដ្ឋ | ២០ ស្លាបព្រាបាយពេញ |
| ប្រេងឆា | ៥ ស្លាបព្រាបាយ |

**របៀបចម្អិន៖**

- ដាក់ឆ្នាំងដាំបបរ
- ស្ងោរត្រី និងបេះយកឆ្អឹងចេញអោយអស់ ហើយពាតត្រីអោយម៉ដ្ឋ
- ចិញ្ច្រាំបន្លែស្លឹកម្រុំអោយម៉ដ្ឋ
- នៅពេលអង្ករពុះ បន្ថយភ្លើង និងបន្តចម្អិនពី ១០ ទៅ ១៥នាទី ហើយកូរម្តងៗដើម្បីកុំអោយខ្លោចបាតឆ្នាំង
- នៅពេលអង្កររីកបន្ថែមសាច់ត្រីនិងបន្តចម្អិន ២ ទៅ ៣នាទី
- បន្ថែមប្រេងឆា និងបន្លែចិញ្ច្រាំម៉ដ្ឋ
- កូរអោយសព្វ និងចម្អិន២ទៅ ៣នាទីទៀត
- ភ្លក្សរសជាតិជាការស្រេច ៕

## មុខអាហារទី ២៖
### បបរដំឡូងផ្វាជាមួយ សណ្តែកដី និង ផ្ទី

| គ្រឿងផ្សំ | ១០ចានចង្កឹះពេញ |
|---|---|
| ដំឡូងផ្វា | ១០ កាចចានចង្កឹះ |
| ទឹក | ៤-៨ ចានចង្កឹះ |
| សណ្តែកដីបុកម៉ដ្ឋ | ២០ ស្លាបព្រាបាយ |
| ផ្ទីចិញ្ច្រាំម៉ដ្ឋ | ២០ ស្លាបព្រាបាយពេញ |

**របៀបចម្អិន៖**

- ដាក់ឆ្នាំងបបរដំឡូងផ្វាហាន់ដុំៗ។ ពេលដំឡូងផ្វាពុះបន្ថយភ្លើងនិងបន្តចម្អិន ១០ ទៅ ១៥នាទី រហូតដល់ដំឡូងផ្វាទន់អាចពាតអោយម៉ដ្ឋបាន
- រើសយកគ្រាប់សណ្តែកដីខូចគុណភាពចេញ លីង អុំយកសំបកចេញ ហើយបុកអោយម៉ដ្ឋ
- ចិញ្ច្រាំផ្ទីអោយម៉ដ្ឋ
- យកសណ្តែកបុកម៉ដ្ឋលាយជាមួយទឹកបបរពាតអោយខាប់ល្មម
- នៅពេលដំឡូងផ្វាពាតម៉ដ្ឋ ហើយបន្ថែមសណ្តែកដីខាប់ចូលនិងបន្តចម្អិន ២ ទៅ ៣នាទី
- បន្ថែមបន្លែចិញ្ច្រាំម៉ដ្ឋ
- កូរអោយសព្វ និងចម្អិន ២ ទៅ ៣នាទីទៀត
- ភ្លក្សរសជាតិជាការស្រេច ៕

# ឧបសម្ព័ន្ធ១៖ បញ្ជីមុខអាហារសម្រាប់ការចម្អិនអាហារបង្ហាញ

## មុខអាហារទី ៣៖
### បបរត្រាវជាមួយ ស៊ុត និង ស្ពៃចង្កឹះ

| គ្រឿងផ្សំ | ១០ចានចង្កឹះពេញ |
|---|---|
| ត្រាវ | ១០ កាចចានចង្កឹះ |
| ទឹក | ៤-៨ ចានចង្កឹះ |
| ស៊ុតក្រឡុក | ២០ ស្លាបព្រាបាយ |
| ស្ពៃចង្កឹះចិញ្ច្រាំម៉ដ្ឋ | ២០ ស្លាបព្រាបាយពេញ |
| ប្រេងឆា | ៥ ស្លាបព្រាបាយ |

**របៀបចម្អិន៖**

- ដាក់ឆ្នាំងបបរត្រាវហាន់ដុំៗ។ ពេលត្រាវពុះបន្ថយភ្លើងនិងបន្តចម្អិន ១០ ទៅ ១៥នាទី រហូតដល់ត្រាវទន់អាចពាតអោយម៉ដ្ឋបាន
- គោះយកសំបកស៊ុតចេញ និងកូរវាយអោយសព្វ
- ចិញ្ច្រាំស្ពៃចង្កឹះអោយម៉ដ្ឋ
- នៅពេលត្រាវពាតម៉ដ្ឋហើយ បន្ថែមស៊ុតក្រឡុកចូលនិងបន្តចម្អិន ២ ទៅ ៣នាទី
- បន្ថែមប្រេងឆា និង បន្លែចិញ្ច្រាំម៉ដ្ឋចូល
- កូរអោយសព្វ និងចម្អិន ២ ទៅ ៣នាទីទៀត
- ភ្លក្សរសជាតិជាការស្រេច៕

## មុខអាហារទី ៤៖
### បបរអង្ករជាមួយ ថ្លើមជ្រូក និង ស្លឹកបាស

| គ្រឿងផ្សំ | ១០ចានចង្កឹះពេញ |
|---|---|
| អង្ករ | ២០ ស្លាបព្រាបាយ |
| ទឹក | ៨ ចានចង្កឹះ |
| ថ្លើមជ្រូកចិញ្ច្រាំ | ២០ ស្លាបព្រាបាយ |
| ស្លឹកបាសចិញ្ច្រាំ | ២០ ស្លាបព្រាបាយពេញ |
| ប្រេងឆា | ៥ ស្លាបព្រាបាយ |

**របៀបចម្អិន៖**

- ដាក់ឆ្នាំងដាំបបរ
- ស្ងោរថ្លើមជ្រូកក្នុងឆ្នាំងជាមួយបបរ។ ពេលឆ្អិនស្រង់ និងចិញ្ច្រាំថ្លើមជ្រូកអោយម៉ដ្ឋ
- ចិញ្ច្រាំបន្លែស្លឹកបាសអោយម៉ដ្ឋ
- នៅពេលអង្ករពុះ បន្ថយភ្លើង និងបន្តចម្អិនពី ១០ ទៅ ១៥នាទី ហើយកូរម្តងៗដើម្បីកុំអោយខ្លោចបាតឆ្នាំង
- នៅពេលអង្កររីកបន្ថែមថ្លើមជ្រូកចិញ្ច្រាំ និងបន្តចម្អិន ៣ ទៅ ៥នាទី
- បន្ថែមប្រេងឆា និងបន្លែចិញ្ច្រាំម៉ដ្ឋ
- កូរអោយសព្វ និងចម្អិន ២ ទៅ ៣នាទីទៀត
- ភ្លក្សរសជាតិជាការស្រេច៕

# ឧបសម្ព័ន្ធ១៖ បញ្ជីមុខអាហារសម្រាប់ការចម្អិនអាហារបង្ហាញ

## មុខអាហារទី ៥៖
### បបរអង្ករជាមួយ សាច់មាន់ និង ត្រកួន

| គ្រឿងផ្សំ | ១០ចានចង្កឹះពេញ |
|---|---|
| អង្ករ | ២០ ស្លាបព្រាបាយ |
| ទឹក | ៨ ចានចង្កឹះ លីត្រ |
| សាច់មាន់ចិញ្ច្រាំម៉ដ្ឋ | ២០ ស្លាបព្រាបាយ |
| ត្រកួនចិញ្ច្រាំម៉ដ្ឋ | ២០ ស្លាបព្រាបាយពេញ |
| ប្រេងឆា | ៥ ស្លាបព្រាបាយ |

**របៀបចម្អិន៖**

- ដាក់ឆ្នាំងបបរ
- ចិញ្ច្រាំសាច់មាន់អោយម៉ដ្ឋ
- ចិញ្ច្រាំបន្លែត្រកួនអោយម៉ដ្ឋ
- នៅពេលអង្ករពុះ បន្ថយភ្លើង និងបន្តចម្អិនពី ១០ ទៅ ១៥នាទី ហើយកូរម្តងៗ ដើម្បីកុំអោយខ្លោចបាតឆ្នាំង
- នៅពេលអង្កររីកបន្ថែមសាច់មាន់ និងបន្តចម្អិន ៣ ទៅ ៥នាទី
- បន្ថែមប្រេងឆា និងបន្លែចិញ្ច្រាំម៉ដ្ឋ
- កូរអោយសព្វ និងចម្អិន ២ ទៅ ៣នាទីទៀត
- ភ្លក្សរសជាតិជាការស្រេច ។៕

## មុខអាហារទី ៦៖
### បាយជាមួយសម្លប្រហើរសាច់ត្រី

| គ្រឿងផ្សំ | បរិមាណ |
|---|---|
| អង្ករ | ០.៨ គីឡូក្រាម |
| ទឹក | ១ លីត្រ |
| សាច់ត្រី | ០.៨ គីឡូក្រាម |
| ល្ពៅ | ០.៣ គីឡូក្រាម |
| ត្រឡាច | ០.៣ គីឡូក្រាម |
| ននោង | ០.៣ គីឡូក្រាម |
| ស្លឹកបាស | ០.១ គីឡូក្រាម |
| ស្លឹកងប់ | ០.១ គីឡូក្រាម |
| ជីស | ៥ ដើម |
| ខ្ទាយ | ១០ មើម |
| រមៀត | ១ មើម |
| ស្លឹកគ្រៃ | ១ ដើម |
| ខ្ទឹមស | ២ កំពឹស |
| ទឹកត្រី | ៣ ស្លាបព្រាបាយ |
| ស្ករត្នោត | ១+១/២ ស្លាបព្រាបាយ |
| អំបិល(អ៊ីយ៉ូដ) | ១ ស្លាបព្រាកាហ្វេ |

**របៀបចម្អិន៖**

- ដាំទឹកសម្លដាក់ខ្ទាយ រមៀត ស្លឹកគ្រៃ ខ្ទឹមសចូលឆ្នាំង
- សម្លពុះ ដាក់ត្រីកាត់ជាកង់ៗ ចូល។ ដាក់ស្ករ និងទឹកត្រី ចូល ហើយពេលពុះ ដាក់បន្លែ តាមលំដាប់លំដោយ។ បន្លែទន់ ដាក់ជីស និងភ្លក្សរសជាតិ។ ថែម ឬថយអំបិលដើម្បីរសជាតិល្អម។

# តារាងអនុសាសន៍ការរៀបចំអាហារ និងបញ្ចុក

## គ្រឿងផ្សំអាហារនៅសម្រាប់ការរៀបចំធ្វើបបរខាប់គ្រប់គ្រឿងទៅតាមអនុសាសន៍សមស្របសម្រាប់ទារក និងកុមារតូចៗ

| គ្រឿងផ្សំ និង បរិមាណបបរខាប់គ្រប់គ្រឿងចម្អិនរួច | បបរ កន្លះចានចង្កឹះ | បបរ កាចចានចង្កឹះ | បបរ ពេញចានចង្កឹះ |
|---|---|---|---|
| អង្ករ | ១ ស្លាបព្រាបាយ | ១ ស្លាបព្រាបាយកន្លះ | ២ ស្លាបព្រាបាយ |
| ទឹក | ២ ចានចង្កឹះ | ២ ចានចង្កឹះកន្លះ | ៣ ចានចង្កឹះ |
| ដំឡូងជ្វា ឬ ត្រាវ | ១ ចានចង្កឹះចែកជាបី | កន្លះចានចង្កឹះ | ១ កាចចានចង្កឹះ |
| ទឹក | ១ ចានចង្កឹះ | ១ ចានចង្កឹះ | ១ ចានចង្កឹះ |
| ត្រីពាតម៉ដ្ឋ ឬ សាច់ចិញ្ច្រាំម៉ដ្ឋ ឬសណ្ដែកដីបុកម៉ដ្ឋ ស៊ុតក្រឡុក ។ល។ | ១ ស្លាបព្រាបាយ | ១ ស្លាបព្រាបាយកន្លះ | ២ ស្លាបព្រាបាយ |
| បន្លែ (ស្លឹកពណ៌បៃតង ឬ ពណ៌លឿង ឬ ពណ៌ទឹកក្រូច ។ល។) | ១ ស្លាបព្រាបាយពេញ | ១ ស្លាបព្រាបាយកន្លះ (ពេញ) | ២ ស្លាបព្រាបាយ (ពេញ) |
| ប្រេងឆា | ១ ស្លាបព្រាកាហ្វេ | ១ ស្លាបព្រាកាហ្វេកន្លះ | ១ ស្លាបព្រាកាហ្វេកន្លះ |

ចំណាំ៖
អ្នកថែទាំកុមារមិនចាំបាច់បន្ថែមប្រេងឆាទេ ប្រសិនបើអ្នកថែទាំកុមារចម្អិនបបរខាប់គ្រប់គ្រឿងដោយប្រើប្រាស់សណ្ដែកដីជំនួសជាតិសាច់។

# តារាងអនុសាសន៍ការរៀបចំអាហារ និងបញ្ចុក

## គ្រឿងផ្សំអាហារដោយយកចេញពីអាហារគ្រួសារ សម្រាប់ការរៀបចំធ្វើបបរខាប់គ្រប់គ្រឿង នៅតាមអនុសាសន៍សមស្របសម្រាប់ទារក និងកុមារតូចៗ

| គ្រឿងផ្សំ និង បរិមាណបបរខាប់<br>គ្រប់គ្រឿងចម្អិនរួច | បបរ កន្លះចានចង្កឹះ | បបរ កាចចានចង្កឹះ |
|---|---|---|
| បាយទន់ (ជ្រាយ) | ជាងកន្លះចានចង្កឹះ | កាចចានចង្កឹះ |
| ទឹកសម្ល | ២ ស្លាបព្រាបាយ | ៣ ស្លាបព្រាបាយ |
| ត្រីពាតម៉ដ្ឋ ឬ សាច់ចិញ្ច្រាំម៉ដ្ឋ ស៊ុត ។ល។ | ១ ស្លាបព្រាបាយកន្លះ | ២ ស្លាបព្រាបាយ |
| បន្លែពណ៌លឿងទុំ ឬ ពណ៌បៃតង | ១ ស្លាបព្រាបាយកន្លះ (ពេញ) | ២ ស្លាបព្រាបាយ (ពេញ) |

## អនុសាសន៍នៃការផ្តល់អាហារដល់កុមារៈ ៦ - ២៤ ខែ

| ក្រុមអាយុ | សណ្ឋានអាហារ | បរិមាណ | ចំនួនដង + អាហារក្រៅពេល | បន្តបំបៅដោះ |
|---|---|---|---|---|
| អាយុ ៦ ខែ | អាហារម្តងមួយមុខៗ ពាតធម៉ដ្ឋ + បបរខាប់គ្រប់គ្រឿង ពាតធម៉ដ្ឋ | ២-៣ ស្លាបព្រាបាយ | ២ | បន្តបំបៅដោះកូន |
| អាយុ ៧ - ៨ ខែ | បបរខាប់គ្រប់គ្រឿង ពាតធម៉ដ្ឋ | កន្លះចានចង្កឹះ | ៣ | បន្តបំបៅដោះកូន |
| អាយុ ៩- ១១ ខែ | បបរខាប់គ្រប់គ្រឿង ពាតធម៉ដ្ឋ ឬ អាហារគ្រួសារ | កាចចានចង្កឹះ | ៣ + ១ | បន្តបំបៅដោះកូន |
| អាយុ ១២ - ២៤ ខែ | បបរខាប់គ្រប់គ្រឿង ឬ អាហារគ្រួសារ | មួយចានចង្កឹះ | ៣ + ២ | បន្តបំបៅដោះកូន |

# ឧបសម្ព័ន្ធ២៖

## តារាងតាមដានសម្រាប់លើកកម្ពស់ការផ្សព្វផ្សាយកែលម្អការចិញ្ចឹមទារក និងកុមារតូចនៅសហគមន៍

ភូមិ..............................ឃុំ..............................ស្រុក..............................    កាលបរិច្ឆេទ:........./........./.........

ចំនួនគ្រួសារដែលចូលរួម:......................................................................    ឈ្មោះអ្នកសម្របសម្រួល:......................................................................

| ល.រ | ព័ត៌មានពីអ្នកថែទាំកុមារ | | | | សមត្ថភាព ការអាននិងសរសេរ | | | | ព័ត៌មានពីកុមារ | | | | កាលបរិច្ឆេទថ្ងៃមេរៀននីមួយៗ | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឈ្មោះអ្នកថែទាំកុមារ | ភេទ | | អាយុ | អាន | | សរសេរ | | ឈ្មោះកុមារ | ភេទ | | អាយុ (ខែ) | ........... | ........... | ........... | ........... | ........... | ........... | ........... |
| | | ស | ប | | អាច | មិន | អាច | មិន | | ស | ប | | លើកទី១ | លើកទី២ | លើកទី៣ | លើកទី៤ | លើកទី៥ | លើកទី៦ | លើកទី៧ |
| ១ | | | | | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | | | | | | | |
| ៧ | | | | | | | | | | | | | | | | | | | |
| ៨ | | | | | | | | | | | | | | | | | | | |
| ៩ | | | | | | | | | | | | | | | | | | | |
| ១០ | | | | | | | | | | | | | | | | | | | |
| ១១ | | | | | | | | | | | | | | | | | | | |
| ១២ | | | | | | | | | | | | | | | | | | | |
| ១៣ | | | | | | | | | | | | | | | | | | | |
| ១៤ | | | | | | | | | | | | | | | | | | | |
| ១៥ | | | | | | | | | | | | | | | | | | | |
| | សរុប | | | | | | | | | | | | | | | | | | |
| | | % | % | | % | % | % | % | | % | % | .......... | % | % | % | % | % | % | % |